ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ៧៣៤/២៥

# របាយការណ៍
## ស្តីពី
## ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី២ ឆ្នាំ២០២៥ និងទិសដៅឆមាសទី១ ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

វិបត្តិសេដ្ឋកិច្ចជាសកល រួមទាំងផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងជាបន្តបន្ទាប់ ដោយបម្រែបម្រួលអាកាសធាតុ ជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ សង្គ្រាមបង្ហូរឈាមរវាងប្រទេស និងប្រទេស ក៏ដូចជាវិបត្តិនយោបាយក្នុងពិភពលោកបច្ចុប្បន្ន វិបត្តិសន្តិសុខស្បៀង និងថាមពល ការលេចចេញនូវប្រភេទជំងឺឆ្លងថ្មី(Nipah Virus) ជាបន្តបន្ទាប់ បានក្លាយជាបញ្ហាចោទចំពោះប្រជាពលរដ្ឋ និងមិនអាចឆ្លើយតបបាន ថាតើពេលណាទើបបញ្ចប់?។ មនុស្សរាប់លាននាក់ ត្រូវបង្ខំចិត្តចាកចេញពីកន្លែងធ្លាប់រស់នៅ ទាំងមិនដឹងថា ត្រូវទៅទីណាដែលមានសុវត្ថិភាព។ ការធ្វើចំណាកស្រុកក្នុងស្ថានភាពបែបនេះ ប្រឈមនឹងកង្វះឯកសារគតិយុត្ត ខ្វះការគ្រប់គ្រង និងការធានាសុវត្ថិភាពពីការរំលោភបំពាន អំពើហិង្សា ការកេងប្រវ័ញ្ច ការលួចឆក់ប្លន់ កុមារប្រឈមនឹងកង្វះការអប់រំ និងអំពើជួញដូរមនុស្ស ដែលបង្កឡើងដោយឧក្រិដ្ឋជន និងជនឆ្លៀតឱកាស ពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ។

ប្រព័ន្ធផ្សព្វផ្សាយកាន់តែសម្បូរបែប កាន់តែទំនើប គួបផ្សំនឹងសេរីភាពនៃព័ត៌មានកាន់តែទូលំទូលាយ តែពិបាកនឹងជឿទុកចិត្ត ដែលលាយឡំដោយព័ត៌មានពិត និងមិនពិត បំផ្លើស និងការបោកបញ្ឆោត។ ទន្ទឹមនេះបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ដូចជា ChatGPT និង Gemini បាននឹងកំពុងទាញយកព្រឹត្តិការណ៍ផ្សេងៗ ទៅប្រើប្រាស់ ក្នុងគោលបំណងកេងប្រវ័ញ្ចគ្រប់រូបភាពពីសំណាក់ជនល្មើស។ ការប្រកួតប្រជែងខាងសេដ្ឋកិច្ច នយោបាយ និងការដណ្តើមភូមិសាស្ត្រនយោបាយ ដើម្បីមហិច្ឆតាជាបងធំក្នុងតំបន់ ឬក្នុងពិភពលោក ធ្វើឱ្យពិភពលោកច្របូកច្របល់ ពុលនឹងសកម្មភាព ឬព័ត៌មានដែលជាការប្រទាញប្រទង់ដណ្តើមយកការគាំទ្រ ទាំងពិត និងមិនពិត។ ប្រទេសកម្ពុជា នៅតែប្រកាន់ជំហរ ឈរលើភាពត្រឹមត្រូវ និងសច្ចធម៌ បើទោះបីជាមានការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលចង់បង្វែរការពិត ទៅជាការបោកបន្លំយ៉ាងណាក៏ដោយ ព្រោះការពិត នៅតែជាការពិត។ កម្ពុជា ជាប្រទេសដែលរងគ្រោះដោយសារតែការប៉ុនប៉ងបំផ្លាញ សន្តិសុខ កេរ្តិ៍ឈ្មោះ និងសេដ្ឋកិច្ច ដែលកម្ពុជា បាននិងកំពុងតែបោះជំហានទៅមុខឥតឈប់ឈរ។ ក្រុមឧក្រិដ្ឋជន ប្រទេសអមិត្តមួយចំនួន បានរៀបចំកលល្បិចបំផ្លាញសន្តិសុខព្រះរាជាណាចក្រកម្ពុជា ដោយបានមកលបលួចឃុបឃិត បោះទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរូបភាព ស្កេមអនឡាញ (Scam Online) និងប្រើកលល្បិចបោកបញ្ឆោតគ្រប់រូបភាពទាក់ទាញពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋពីបណ្តាប្រទេសមួយចំនួន ឱ្យចូលមកប្រព្រឹត្តបទល្មើសនៅកម្ពុជា និងបានធ្លាក់ចូលក្នុងភាពរងគ្រោះ ដោយការប្រើហិង្សា ធ្វើការងារដោយបង្ខំ ការកេងប្រវ័ញ្ចពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដោយទាញយកផលប្រយោជន៍យ៉ាងមហាសាល ពីការបោកប្រាស់មនុស្សទាំងឡាយនៅក្រៅប្រទេស។ សកម្មភាពទាំងនេះ បានជះឥទ្ធិពលជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ ព្រះរាជាណាចក្រកម្ពុជា យ៉ាងធ្ងន់ធ្ងរថាជាប្រទេសដែលមានឧក្រិដ្ឋកម្ម ស្កេមអនឡាញ (Scam Online) និងគ្មានសុវត្ថិភាព ។

ទំនាស់ព្រំដែនដែលបង្កឡើងដោយរដ្ឋាភិបាល និងយោធាសៀមឈ្លានពាន បានក្លាយជាសង្គ្រាមបង្វែរឈាម សង្គ្រាមសេដ្ឋកិច្ច និងសង្គ្រាមនយោបាយការទូត យ៉ាងស្វិតស្វាញ គួបផ្សំនឹងក្រុមជាតិនិយមជ្រុល ដែលយាយី រំខានពលករកម្ពុជាដោយការរើសអើងពូជសាសន៍ ការប្រើហិង្សាលើរូបរាងកាយ ការជេរប្រមាថ បណ្តេញ កេងប្រវ័ញ្ច មិនបើកប្រាក់ឈ្នួល គួបផ្សំនឹងការគំរាមបិទព្រំដែនជាច្រកសេដ្ឋកិច្ចជាដើម បានជំរុញឱ្យពលករខ្មែរ មិនអាចទ្រាំទ្រ ឬរស់នៅ និងធ្វើការក្នុងប្រទេសថៃបាន ហើយត្រូវបង្ខំចិត្តរត់គេចចេញពីប្រទេសថៃ ដោយបានយកតាមខ្លួនត្រឹមតែ សម្ភារៈតិចតួចជាប់ខ្លួន រហូតដល់ទៅ ជាងប៉ែតសិបម៉ឺននាក់ ក្នុងចំណោមពលរដ្ឋខ្មែរវិលត្រឡប់ប្រមាណ មួយលាននាក់ ក្នុងរយៈពេលតែប្រមាណជិតបួនខែប៉ុណ្ណោះ។ នៅមានពលករខ្មែរ ប្រមាណជាង សែសិបម៉ឺននាក់ទៀត ដែលភាគច្រើន ធ្វើការនៅលើផ្នែកកសិកម្ម ឧស្សាហកម្ម សំណង់ និងតាមរោងចក្រ សហគ្រាសមួយចំនួន។ ដោយឡែកអាជីវករ និង ពាណិជ្ជករមួយចំនួន ដែលមានទំនាក់ទំនងសេដ្ឋកិច្ច ក្នុងការនាំទំនិញ ចេញ-ចូលពីប្រទេសថៃ ក៏ត្រូវទទួលរងផល ប៉ះពាល់ពីការបិទព្រំដែនដែរ។ បន្ថែមលើសពីនេះ អំពើឈ្លានពានដ៏សាហាវ យង់ឃ្នង និងខុសច្បាប់ ដែលបង្កឡើង ដោយកងទ័ពថៃ តាំងតែពីថ្ងៃទី ០៧ រហូតមកដល់ចុងខែធ្នូ ឆ្នាំ២០២៥ មកលើបូរណភាពទឹកដី នៃព្រះរាជាណាចក្រ កម្ពុជា បានបើកការវាយប្រហារយ៉ាងខ្លាំងក្លា និងដោយឥតរើសមុខ ដោយប្រើប្រាស់ កាំភ្លើងធំធុនធ្ងន់ យន្តហោះ ចម្បាំងគ្រប់ប្រភេទ F-16 និង T-50TH ព្រមទាំងអាវុធដទៃទៀត មកលើប្រជាជនស៊ីវិល នៅតាមបណ្តាខេត្តជាប់ព្រំដែន ដែលបណ្តាលឱ្យមានជនភៀសសឹកជាងកន្លះលាននាក់ ត្រូវបានជម្លៀសចេញពីលំនៅដ្ឋាន រួមមានទាំងស្ត្រី និងកុមារ ផងដែរ។ ដែលរហូតមកដល់ដំណាច់ឆ្នាំ ២០២៥ នេះ ទោះបីបទឈប់បាញ់ បានចូលជាធរមានក៏ដោយ ក៏ជនភៀស សឹកមិនទាន់បានវិលត្រឡប់ទាំងស្រុងទៅកាន់លំនៅដ្ឋាន ដែលជាភូមិកំណើតរបស់ខ្លួននៅឡើយទេ ដោយសារតែ លំនៅដ្ឋាន ជាភូមិកំណើតរបស់ពួកគេ បាននឹងកំពុងតែកាន់កាប់ដោយខុសច្បាប់ពីកងទ័ពថៃ ។

នៅក្នុងស្ថានភាពដ៏លំបាក និងឥតព្រាងទុកនេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ក្រោមការដឹកនាំដ៏ ឈ្លាសវៃ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្រមតាមគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ បានដាក់ចេញ នូវវិធានការគន្លឹះជាបន្ទាន់ ដើម្បីដោះស្រាយជីវភាពពលករខ្មែរ ដែលបានវិលត្រឡប់ ដោយការបង្កើនឱកាស ការងារ និងមុខរបរ ដែលអាចស្រូបទាញដោយ រោងចក្រ សហគ្រាស ក្រុមហ៊ុន ដែលបានវិនិយោគនៅកម្ពុជា និង ការបង្កលក្ខណៈក្នុងការបង្កើតមុខរបរខ្នាតតូច ឬមធ្យម ទៅតាមកម្រិតវ័យ មុខជំនាញ ចំណង់ចំណូលចិត្ត និង សមត្ថភាព ឬទេពកោសល្យ និងដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋខ្មែរ ដែលជាជនភៀសសឹកដោយសារ អំពើឈ្លានពានដ៏សាហាវ យង់ឃ្នង និងខុសច្បាប់ បង្កឡើងដោយកងទ័ពថៃ ដែលបានបំផ្លាញផ្ទះសំបែងជាច្រើនខ្នង សិស្សសាលា ក្មេងចាស់ ប្រុសស្រី ត្រូវបង្ខំចិត្តភៀសខ្លួនរកទីកន្លែងមានសុវត្ថិភាពបណ្តោះអាសន្នភ្លាមៗ។ បញ្ហា ប្រឈមជាច្រើន ត្រូវបានដោះស្រាយ អាស្រ័យដោយមានការចូលរួមជាធ្លុងមួយ ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការដៃគូនានា ទៅតាមវិស័យជំនាញរៀងៗខ្លួនយ៉ាង សកម្ម និងស្រុះដៃគ្នា ជាពិសេសសាមគ្គីឯកភាពជាតិនៃប្រជាពលរដ្ឋខ្មែរ។ នេះជាមោទនភាព របស់ ប្រជាជាតិខ្មែរ ដែលមានការជឿទុកចិត្ត រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទ្រោលសភាពការណ៍ដ៏លំបាកនេះ ។

បើទោះបីជាបទល្មើសជួញដូរមនុស្ស បទល្មើសឆបោកតាមប្រព័ន្ធអនឡាញ និងបទល្មើសពាក់ព័ន្ធដទៃ ទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន កើនឡើងគ្រប់ទីកន្លែងអាស្រ័យដោយស្ថានភាព ប្រែប្រួលពិបាកប៉ាន់ស្មាននៃ វិបត្តិនយោបាយ សេដ្ឋកិច្ច សន្តិសុខ សង្គ្រាម និងគ្រោះធម្មជាតិ ដែលកើតមានចំពោះព្រះរាជាណាចក្រកម្ពុជា ក៏ដូច ជានៅក្នុងតំបន់ និងក្នុងពិភពលោកក្តី ក៏គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព នៅថ្នាក់ជាតិ រាជធានី ខេត្ត និងមានការចូលរួមគាំទ្រ សហការ ពីអង្គការដៃគូជាតិ និងអន្តរជាតិ ពាក់ព័ន្ធផង បានធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ ដែលបានធ្វើឡើងតាមយុទ្ធសាស្ត្រ ដែលបានកំណត់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រព្រឹត្តទៅយ៉ាងសកម្ម និងឆ្លើយតបបានទាន់សភាពការណ៍គួរឱ្យមោទនៈ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ៩១.១៤៩លើក មានអ្នកចូលរួមចំនួន ៤.៧៤៤.៩៧៧នាក់ ក្នុងនោះស្ត្រី ២.៤៨៨.៥៩២នាក់ (ប្រៀបធៀបធមាសទី២ ឆ្នាំ២០២៤ មានចំនួន ៤.២៦៣.១៣៧នាក់) កើនឡើង ៤៨១៨៤០នាក់ ស្មើនឹង ១១,៣០% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស | ០៣ | ៣.០៩៧ | ៩០៤ |
| ២ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ៨៩.៥០៩ | ៤.៣៤៧.៥២៤ | ២.៣០៥.៧៣៣ |
| ៣ | កម្មវិធីផ្សេងៗ | ១.៦៣៧ | ៣៩៤.៣៥៦ | ១៨១.៩៥៥ |
| សរុប | | ៩១.១៤៩លើក | ៤.៧៤៤.៩៧៧នាក់ | ២.៤៨៨.៥៩២នាក់ |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)*

❖ **ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ២០សីហា**

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយ ក្រសួងធម្មការនិងសាសនា និងមេដឹកនាំនិកាយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា (សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រីស្ត) រៀបចំកម្មវិធីទិវាជាតិអន្តរសាសនាលើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ "សុខដុមរមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នាសម័យបច្ចេកវិទ្យា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ **កៃ សួនសុភី ស សុខា** ជាទីគោរពដ៏ខ្ពង់ខ្ពស់។ មានអ្នកចូលរួមប្រមាណ ២.៤៨៥អង្គ/នាក់ (ស្រី ៧០៩នាក់) នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ(OCIC) រាជធានីភ្នំពេញ។

▪ **ខេត្តសៀមរាប និងខេត្តស្វាយរៀង៖** លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយមន្ទីរធម្មការ និងសាសនាខេត្ត និងអង្គការដៃគូ រៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា» ដោយមានការនិមន្តចូលរួម ពីតំណាងសាសនាព្រះពុទ្ធទាំងពីរគណៈ សាសនាឥស្លាម សាសនាគ្រីស្តពីរនិកាយ ពុទ្ធសាសនាមហាយាន និងតំណាងមន្ទីរ អង្គភាព ស្ថាប័ន គណៈអភិបាលក្រុង ស្រុក ចៅសង្កាត់ និងអង្គការដៃគូជាតិ-អន្តរជាតិ សរុបជាង ៦១២អង្គ/នាក់ (ស្រី ១៩៥នាក់)។

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ថ្នាក់ជាតិ** | | | | | | | |
| ១ | គ.ជ.ប.ជ | ៣១ | ៣.៤១៤ | ១.១៣២ | | | |
| **រាជធានី ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៣៦១ | ៦៨.៨២៧ | ៣០.៥៣០ | ១០១ | ៥.៩៩៩ | ៣.១៣៩ |
| ២ | កណ្ដាល | ១.៥២៣ | ១៧១.០៤៨ | ៦៩.៥៦៨ | ៨៥៤ | ២៥.១៨៥ | ១៣.៥២៩ |
| ៣ | បាត់ដំបង | ៤.៨៤៤ | ២៣៦.៦៩២ | ១៣៣.៣៣៥ | ៣.៩៥២ | ១៣៥.៩៩៤ | ៨១.៨៣៣ |
| ៤ | ពោធិ៍សាត់ | ៣.៧៧៨ | ៣៦៩.៥៧៨ | ១៨៧.១៤១ | ២.១៥៦ | ៨៥.៥៩០ | ៣៨.៤១០ |
| ៥ | សៀមរាប | ៤.៨៧៧ | ៣២៧.៩៦៧ | ២១២.៦៨២ | ៤.៣១៨ | ១៧៩.៦៥៧ | ១១១.៧៨៤ |
| ៦ | កំពង់ឆ្នាំង | ៤.៥៥០ | ១៧៧.៦៤៩ | ៨៨.០៤៧ | ២.១០៤ | ៧៦.៨៣០ | ៣៨.៣៩៨ |
| ៧ | កំពង់ចាម | ១០.២៦៩ | ៦០០.៩៥៨ | ៣០៣.៥៤៧ | ០៥ | ៦១៦ | ៣៣៩ |
| ៨ | ព្រះសីហនុ | ២.៥៤៤ | ៧៧.៦២២ | ៣៤.០៧៩ | ១.០១៥ | ៣២.០៨២ | ១៥.១៦១ |
| ៩ | ព្រះវិហារ | ១៦២ | ១៦.៩៧៨ | ១០.០៤២ | ០៦ | ១.៦១៩ | ៥០១ |
| ១០ | ស្វាយរៀង | ២.១៥៩ | ៩២.៥៥៤ | ៥៥.៧០៣ | ២.៦៩៣ | ១២១.៩៤២ | ៨០.៥៥០ |
| ១១ | ប៉ៃលិន | ០៧ | ១.៤៣៦ | ៧៥២ | ៥៦៨ | ២០.៦១០ | ៩.៩០៥ |
| ១២ | កោះកុង | ៨.៥៩៩ | ១៣៨.៤៥៥ | ៦២.៦៩៩ | ២.០៨៨ | ៣៥.៥៩៨ | ១៥.០៩៩ |
| ១៣ | កំពត | ៦៦ | ៥.៣៣១ | ២.៥៤១ | ៣១ | ១.០៦៤ | ៥៦៧ |
| ១៤ | កំពង់ធំ | ៦៥៦ | ៤១.៦៣០ | ២៥.០២៥ | ២២៩ | ៩.១០៧ | ៥.២៨៧ |
| ១៥ | តាកែវ | ១.៧៣៥ | ២៤៥.៣២៨ | ១២០.៦៣៥ | | | |
| ១៦ | ក្រចេះ | ៣៨៦ | ១១.២០៥ | ៥.៣៤៣ | | | |
| ១៧ | កែប | ១១២ | ១៨.០៧៨ | ៨.៤១៦ | ២២០ | ៩.៤៦៧ | ៥.២៨៧ |
| ១៨ | កំពង់ស្ពឺ | ២.៨៦២ | ១៣៩.៨៩៤ | ៧៧.២៥៨ | ៧៦៩ | ២៩.៨៧៨ | ១៦.៧១៧ |
| ១៩ | ស្ទឹងត្រែង | ៨៨៤ | ៥៦.៣៧៧ | ៣០.៤៣៨ | ៧៤២ | ២៥.៧១០ | ១៤.៤៨៥ |
| ២០ | រតនគិរី | ១.៨៥៧ | ៧៩.២២០ | ៣៩.៤២១ | ៩១០ | ៤៥.១១៨ | ១៧.២២៥ |
| ២១ | ព្រៃវែង | ៦.២៥៤ | ៣១១.៦៤៦ | ១៧៩.៦២០ | ៣.៩៦៣ | ១៥១.៦៤២ | ៨៣.០៩៧ |
| ២២ | ត្បូងឃ្មុំ | ៩៨ | ៧.១៤០ | ៣.៩០៥ | ១.២១៤ | ៣៧.២១៥ | ១៦.៦៩៤ |
| ២៣ | បន្ទាយមានជ័យ | ១.០០៤ | ១៩.២៨៨ | ១០.៧២៣ | ៣០០ | ៧.៩៤៦ | ៤.៧៤៤ |
| ២៤ | ឧត្ដរមានជ័យ | ៨៦៥ | ៤២.៩៣២ | ២៥.០៦៣ | ២២១ | ២៨.៧៦២ | ៦.៤៣៤ |
| ២៥ | មណ្ឌលគិរី | ៤៨៥ | ១៤.៩៤៥ | ៧.១៦៦ | ៨២ | ៣.៧០១ | ១.៧៣៧ |
| សរុប រាជធានី-ខេត្ត | | ៦០.៩៣៧លើក | ៣.២៧២.៧៧៨នាក់ | ១.៧២៣.៦៧៩នាក់ | ២៨.៥៤១លើក | ១.០៧១.៣៣២នាក់ | ៥៤០.៩២២នាក់ |
| សរុបរួម | | ៨៩.៥០៩លើក | | ៤.៣៤៧.៥២៤នាក់ | | ២.៣០៥.៧៣៣នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ២៩ | ១៤.៨៧៥ | ៦.៦៨៤ |
| ២ | ខេត្តបាត់ដំបង | ៧៧ | ៤.១៧២ | ១.៦៨៥ |
| ៣ | ខេត្តប៉ៃលិន | ០៩ | ៤.២១២ | ២.៣៦៤ |
| ៤ | ខេត្តសៀមរាប | ៣៥២ | ១៨.៨១៥ | ១០.៤២៥ |
| ៥ | ខេត្តកំពង់ឆ្នាំង | ០៦ | ២០១ | ៩៧ |
| ៦ | ខេត្តកំពង់ចាម | ០៤ | ២៧២ | ១៥២ |
| ៧ | ខេត្តព្រះវិហារ | ០៣ | ៦៩ | ២២ |
| ៨ | ខេត្តព្រៃវែង | ១០ | ២.៨៣០ | ១៧៨ |
| ៩ | ខេត្តត្បូងឃ្មុំ | ១៤ | ២.៣៥៣ | ៨៦៨ |
| ១០ | ខេត្តឧត្ដរមានជ័យ | ៦២៨ | ២៤.៦៦៧ | ១៤.៩៣៩ |

| | | | | |
|---|---|---|---|---|
| ១១ | ខេត្តកំពង់ស្ពឺ | ៦៣ | ៣០.៤៤៥ | ៩៥៥ |
| ១២ | ខេត្តមណ្ឌលគិរី | ០១ | ១៧៥ | ៨៣ |
| ១៣ | ខេត្តតាកែវ | ១៦១ | ២៨១.៩៤៥ | ១៣៨.៩៤៥ |
| ១៤ | ខេត្តកែប | ០២ | ៦៥៧ | ៣២៥ |
| ១៥ | អង្គការសាម៉ារីតាន់(បាត់ដំបង) | ០៨ | ២.០០៥ | ១.១៦២ |
| ១៦ | អង្គការ Friend International (សៀមរាប) | ១៩៦ | ២.៩៩០ | ១.៤៨២ |
| ១៧ | អង្គការមូលនិធិA21(សៀមរាប) | ៥៩ | ៣.០១៧ | ១.៥៥៥ |
| ១៨ | អង្គការម្លប់តាប៉ាង(ព្រះសីហនុ) | ០៨ | ៧១០ | ១០៦ |
| ១៩ | អង្គការជលធារជីវិត(ព្រះសីហនុ) | ០៥ | ៤០០ | ១៤០ |
| ២០ | អង្គការដំណក់ទឹក(បន្ទាយមានជ័យ) | ០៣ | ១៤៨ | ៨០ |
| ២១ | អង្គការហាជហុក(ប៉ៃលិន) | ០១ | ៥៥ | ៣៣ |
| សរុប | | ១.៦៣៧លើក | ៣៩៤.៣៥៦នាក់ | ១៨១.៩៥៥នាក់ |

**ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់**

❖ **ការផលិត និងចែកផ្សាយសម្ភារផ្តល់ព័ត៌មាន និងអប់រំ IEC (Information Education Communication Materials)**

| ល.រ | រាជធានី-ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៥៦.៧៨៩ប័ណ្ណ | | |
| ២ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៦.៨៧៣ប័ណ្ណ | | |
| ៣ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៤.១១៥ប័ណ្ណ | | |
| ៤ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.៧៤២នាក់ | ៦៧៨នាក់ |
| ៥ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-ចងបដាផ្សព្វផ្សាយ | ៥៦ប័ណ្ណ<br>០៤ផ្ទាំង | ២.៤១២នាក់ | ៦៧៦នាក់ |
| *សរុបខិត្តប័ណ្ណផ្សព្វផ្សាយ ៦៧.៨៣៣ប័ណ្ណ ចងបដាផ្សព្វផ្សាយ ០៤ផ្ទាំង អ្នកទទួលបាន ៤.១៥៤នាក់ ស្ត្រី១.៣៥៤នាក់* | | | | | |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ប៉ុត | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | គ.ជ.ប.ជ | -បណ្តាញទូរស័ព្ទ | ០១ | |
| ២ | សៀមរាប | -វិទ្យុជាតិ<br>-សម្តែងរឿងខ្លី ខ្សែភាពយន្តវីដេអូអប់រំ | ៦៨៤<br>០៧ | ១.១១០(ស្រី១០០) |
| ៣ | កំពង់ចាម | -វិទ្យុជាតិ | ៩០០ | |
| ៤ | ព្រៃវែង | -វិទ្យុជាតិ | ៣០០ | |
| ៥ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ១៦០ | |
| ៦ | ប៉ៃលិន | -វិទ្យុជាតិ | ២.៤៨០ | |
| ៧ | បន្ទាយមានជ័យ | -វិទ្យុជាតិ | ២០ | |
| សរុប | | | ៤.៥៥២ លើក | ១.១១០(ស្រី១០០) |

❖ ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍

| ល.រ | ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | វិទ្យុ ទូរទស្សន៍ និងផ្សេងៗ | ចំនួនលើក |
|---|---|---|---|
| ១ | គ.ជ.ប.ជ | -លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ បានអញ្ជើញជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីសន្ទនាមតិ «ជីវិតយើង សង្គមយើង» ប្រធានបទ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល ផ្សាយចេញពីវិទ្យុជាតិកម្ពុជា នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា<br>-ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ វណ្ណារ៉ា អគ្គលេខាធិការរង បានផ្តល់បទសម្ភាសជូនអង្គការ Terre des Hommes Netherland ពាក់ព័ន្ធយន្តការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសការងារប្រយុទ្ធប្រឆាំងការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ | ០២ |
| ២ | ខេត្តសៀមរាប | -តំណាងមន្ទីរកិច្ចការនារី ជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ស្តីពីការស្វែងយល់ពីអាពាហ៍ពិពាហ៍ក្នុងសង្គមខ្មែរ ១លើក<br>-តំណាងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ស្តីពីការបណ្តុះបណ្តាលបច្ចេកទេស ចិញ្ចឹមសត្វ និងដាំបន្លែដល់ពលករដែលវិលត្រឡប់ពីក្រៅប្រទេស ១លើក<br>-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ២លើក ស្តីពីៈការលើកទឹកចិត្តដល់ពលករ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ ឱ្យធ្វើការនៅកម្ពុជាវិញ និងដំណើរការទទួលនិយត្រៀមកន្លែងការងារសមាប់ពលករមកពីថៃ<br>-តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ ជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ការផ្តល់កម្ចីឥណទានសម្រាប់បង្កើនមុខរបរ ដល់ពលករចំណូលស្រុក១លើក<br>-តំណាងវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ ជាវាគ្មិនកម្មវិធីសន្ទាមតិវិទ្យុជាតិនគរភ្នំ ស្តីពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈប្រជាពលរដ្ឋ និងពលករខ្មែរនៅប្រទេសថៃ ដែលវិលត្រឡប់មកស្រុកកំណើត ១លើក<br>-ស្នងការដ្ឋាននគរបាលខេត្ត ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ២លើក ស្តីពីវិធានការបង្ក្រាបបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព នៅក្នុងខេត្ត និងការផ្សព្វផ្សាយអំពីអំពើកេងប្រវ័ញ្ច និងការជួញដូរមនុស្ស<br>-អធិការក្រុងរុនតាឯកតេជោសែន ជាវាគ្មិនកម្មវិធីសន្ទាមតិវិទ្យុជាតិនគរភ្នំ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ក្នុងក្រុងរុនតាឯកតេជោសែន ១លើក<br>-ប្រធានមជ្ឈមការងារ ជាវាគ្មិនក្នុងកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ២លើក ការផ្តល់ឱកាសការងារក្នុងស្រុក ដើម្បីកាត់បន្ថយចំណាកស្រុកក្រៅប្រទេស អំឡុងពេលមានបញ្ហាព្រំដែន និងការត្រៀមស្វែងរកការងារ ដល់ពលករវិលត្រឡប់មកពីប្រទេសថៃ<br>-ប្រធានការិយាល័យស្រាវជ្រាវមុខរបរ និងទំនាក់ទំនងឧស្សាហកម្ម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោ សែនសៀមរាប ជាវាគ្មិនកម្មវិធីសន្ទាមតិ វិទ្យុជាតិនគរភ្នំ ស្តីពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់ពលករដែលវិលត្រលប់មកពីក្រៅប្រទេស ១លើក<br>-រដ្ឋបាលស្រុកពួក ជាវាគ្មិនកម្មវិធីសន្ទាមតិវិទ្យុជាតិនគរភ្នំ ស្តីពីការគាំទ្រស្ត្រីឱ្យមានការងារក្រោយវិលមកពីក្រៅប្រទេស ១លើក | ១៦ |

| | | | |
|---|---|---|---|
| | | -រដ្ឋបាលស្រុកក្រឡាញ់ ជាវាគ្មិនកម្មវិធីសន្ទនាមតិវិទ្យុជាតិនគរភ្នំ ស្ដីពីការជួយសម្របសម្រួលដល់ជនភៀសសឹកនៅក្នុងស្រុក ១លើក<br>-រដ្ឋបាលស្រុកអង្គរជុំ ជាវាគ្មិនកម្មវិធីសន្ទនាមតិវិទ្យុជាតិនគរភ្នំ ស្ដីការគាំទ្រស្ដ្រីឱ្យមានការងារធ្វើក្រោយវិលត្រឡប់មកពីក្រៅប្រទេស ១លើក<br>-អង្គការមូលនិធិអេ២១ ជាវាគ្មិនកម្មវិធី "យើងធ្វើបាន" វិទ្យុជាតិនគរភ្នំ ស្ដីពីបច្ចេកវិទ្យា និងការរំលោភបំពានផ្លូវភេទលើស្ដ្រី និងក្មេងស្រី | |
| ៣ | ខេត្តបាត់ដំបង | -តំណាងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត ជាវាគ្មិន ៤លើក<br>○ កម្មវិធីសន្ទនាមតិ ស្ដីពីផ្ដល់ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈនិងឱកាសការងារដល់ពលករត្រឡប់មកពីប្រទេសថៃ នៅវិទ្យុជាតិខេត្ត ២លើក<br>○ កម្មវិធីវេទិកាសំណួរចម្លើយ ស្ដីអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងព័ត៌មានវគ្គបណ្ដុះបណ្ដាល ជំនាញវិជ្ជាជីវៈ នៅស្រុកសង្កែ<br>○ កម្មវិធីជជែកពិភាក្សា ស្ដីពីទីផ្សារការងារ និងបញ្ហាប្រឈមក្នុងការស្វែងរកការងារដល់សិស្សានុសិស្ស របស់គម្រោងយុវជនឆ្នើម នៃអង្គការពុទ្ធិកុមារ | ០៤ |
| ៤ | ខេត្តកំពង់ចាម | -តំណាងស្នងការដ្ឋាននគរបាលខេត្ត ជាវាគ្មិនកម្មវិធីសន្ទនាមតិ វិទ្យុជាតិខេត្ត<br>○ ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ<br>○ ដំណើរការទទួលនិងត្រៀមកន្លែងការងារសម្រាប់ពលករមកពីប្រទេសថៃ | ០២ |
| | សរុប | | ២៣លើក |

## ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ក.៣.១ ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖ កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន ២៩លើក មនុស្សចំនួន ៣៣២នាក់ ស្រី ១៥៤នាក់ ដោយបានធ្វើកិច្ចសន្យាអប់រំណែនាំ និងឱ្យត្រឡប់ទៅភូមិកំណើតវិញ។

### ក.៣.២. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ចំនួន ១.១៤៣នាក់ ស្រី ៤៣នាក់ មាន២៦សញ្ជាតិ៖ ចិន៧៤៨, កូរ៉េខាងត្បូង១៩៨ស្រី២១, អាមេរិក៧៧ស្រី៧, បារាំង៣០ស្រី២, ម៉ាឡេស៊ី១៨ស្រី១, អូស្ត្រាលី១៥ស្រី៤, កាណាដា១០, វៀតណាម៩ស្រី៣, ឥណ្ឌូនេស៊ី៦, អាល្លឺម៉ង់៦, ឡាវ៤(ស្រី), ជប៉ុន៣, ហូឡង់៣, រុស្ស៊ី២ស្រី១, ស្រីលង្កា២, ហ្វាំងឡង់២, អង់គ្លេស១, ស្វីស១, ទួគី១, ម៉ាល់១, ឆែក១, អូទ្រីស១, ញូហ្ស៊ីឡែន១, អៀរឡង់១, នេប៉ាល់១ និងអាហ្វ្រិកខាងត្បូង១។ *បានវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះ ប្រកបេញ-ចូលតែមួយចំនួន ៨៩១នាក់ ស្រី ៣៩នាក់។*

### ក.៣.៣. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់ពីក្រៅប្រទេសវិញ ទូទាំងរាជធានី ខេត្តទាំង២៥៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| កក្កដា | ១២៩.៧២២ នាក់ | ៥៨.០៥៦ នាក់ | ៥.១១៦ នាក់ | ១.៦២៥ នាក់ |

| | | | | |
|---|---|---|---|---|
| សីហា | ១១៧.៧៤៩ នាក់ | ៥១.០៦៨ នាក់ | ៤.៩២៧ នាក់ | ១.៥២៧ នាក់ |
| កញ្ញា | ១០៥.១៤៩ នាក់ | ៤៦.០០៨ នាក់ | ៣.៩០៩ នាក់ | ១.១៨៦ នាក់ |
| តុលា | ៩៦.១៧៣ នាក់ | ៤២.២១៧ នាក់ | ៣.៨១០ នាក់ | ១.១៥៣ នាក់ |
| វិច្ឆិកា | ៥៦.២៦៩ នាក់ | ២៣.៧០៨ នាក់ | ៤២៥ នាក់ | ៨៧ នាក់ |
| ធ្នូ | ៤៩.៤៩៣ នាក់ | ២០.១៦៤ នាក់ | ២៩០ នាក់ | ៩៤ នាក់ |
| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| កក្កដា | ១៤.៦៨៤ នាក់ | ៦.០១៩ នាក់ | ២១២ នាក់ | ៧៩ នាក់ |
| សីហា | ២៧.២៨០ នាក់ | ១២.៧២៦ នាក់ | ៦៧៧ នាក់ | ២១៥ នាក់ |
| កញ្ញា | ១១៣.២៤៨ នាក់ | ៥០.៧៣៥ នាក់ | ៣.០៤៧ នាក់ | ៧៤១ នាក់ |
| តុលា | ៨០.៧២៤ នាក់ | ៤២.១៩៨ នាក់ | ១.៦២៣ នាក់ | ៦៣២ នាក់ |
| វិច្ឆិកា | ៥១.៩៣៧ នាក់ | ២៣.៣៦៥ នាក់ | ៨៧៧ នាក់ | ៣៤៤ នាក់ |
| ធ្នូ | ២១.៥៦៤ នាក់ | ៩.០០៧ នាក់ | ៣៥៩ នាក់ | ១៣៨ នាក់ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន

| ល.រ | ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៣.៩៣៨ | ១.៣៣៧ | ០៥ | |
| ២ | បាត់ដំបង | ១.២៥៦ | ៤៨៦ | ១២៨ | |
| ៣ | កោះកុង | ៣៦ | ០៦ | | |
| ៤ | ប៉ៃលិន | ១០.៤៤២ | ៤.៦៨២ | | |
| ៥ | ស្វាយរៀង | ៣៤ | ២៦ | ១០ | ០៨ |
| ៦ | តាកែវ | ០១ | | | |
| | សរុប | ១៥.៧០៧នាក់ | ៦.៥៣៧នាក់ | ១៤៣នាក់ | ០៨នាក់ |

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករខ្មែរចំណាកស្រុកដែលបញ្ជូនត្រឡប់ពីប្រទេសថៃនិរទេស សរុបចំនួន ៣.២៨២នាក់ (ប្រុស១.៧៣៣នាក់ ស្រី១.១២៤នាក់ កុមារា ២២៥នាក់ កុមារី២០០នាក់)។

▪ មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង បានទទួលពលករខ្មែរបញ្ជូនត្រលប់ពីអាជ្ញាធរថៃ សរុបចំនួន ២.៤៥០នាក់ ក្នុងនោះស្ត្រី ៨៨២នាក់ (ស្ត្រីមានកូនតូចមកជាមួយ ១៤៥នាក់ និងស្ត្រីមានផ្ទៃពោះ ៣២នាក់) អនីតិជន ១៣៦នាក់ (អនីតិជនស្រី ៦៧នាក់) និងជនមានពិការភាព ០៦នាក់(ស្ត្រី ០១នាក់)។

**ក.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ **ការផ្សព្វផ្សាយ**

▪ ខេត្តសៀមរាប៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះជ្រើសរើស និងកំណត់អត្តសញ្ញាណកុមារងាយរងគ្រោះ ដែលមានអាណាព្យាបាលកំពុងធ្វើការនៅតាមសិប្បកម្មផលិតឥដ្ឋ ដើម្បីផ្តល់ការគាំទ្រពីគម្រោងកិច្ចអន្តរាគមន៍ស្នូល នៅក្នុងស្រុកអង្គរធំ, បន្ទាយស្រី, ក្រឡាញ់, សូទ្រនិគម និងស្រុកជីក្រែង ក្នុងនោះមាន

១៥សិប្បកម្ម ដែលមានកុមារសរុប ២៣៧នាក់ ស្រី ១១៥នាក់។ ជាលទ្ធផលកុមារដែលត្រូវទទួលបានពីគម្រោង មាន១៣០នាក់ ស្រី ៦៤នាក់ កុមារត្រូវទប់ស្កាត់ និងការពារ ៨០នាក់ ស្រី ៣៩នាក់ និងកុមារបន្តការគាំពារ ៥០នាក់ ស្រី ២៥នាក់ នៅក្នុងស្រុកបន្ទាយស្រី ស្រុកក្រឡាញ់ និងស្រុកសូទ្រនិគម។

▪ **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងចងបដាផ្សព្វផ្សាយតាមសហគ្រាស គ្រឹះស្ថានក្នុងវិស័យផលិតផង និងក្បឿងចំនួន ៧៥សហគ្រាស/គ្រឹះស្ថាន នៅក្នុងក្រុង/ស្រុកទាំង៥ ដែលមានកម្មករនិយោជិតចំនួន ១.៦៦៩នាក់ ស្រី៨១៦នាក់ និងមានកម្មករនិយោជិតវ័យក្មេង(អាយុ១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ)ចំនួន ៣០៣នាក់ ស្រី ១៤៤នាក់ និងមានកុមាររស់នៅជុំវិញបរិវេណសហគ្រាស គ្រឹះស្ថានចំនួន ១.១៣៦នាក់ ស្រី៥៦៨នាក់។ ក្នុងនោះមន្ទីរធ្វើកិច្ចសន្យាហាមឃាត់ប្រើប្រាស់ពលកម្មកុមារ ជាមួយម្ចាស់សហគ្រាស គ្រឹះស្ថាន បានចំនួន ៧៥សហគ្រាស/គ្រឹះស្ថាន ព្រមទាំងបានធ្វើកិច្ចសន្យាជាមួយអាណាព្យាបាលចំនួន ៦៩៤គ្រួសារ។

❖ **អធិការកិច្ច**

▪ **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើអធិការកិច្ចការងារចំនួន ៤០លើក អធិការកិច្ចការងារតាមកម្មវិធី ៣៥លើក និងអធិការកិច្ចការងារពិសេស ០៥លើក។ ធ្វើអធិការកិច្ចការងារតាមកម្មវិធីចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស លក្ខខណ្ឌការងារ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសិប្បកម្មផលិតផងបាន ៣៥សិប្បកម្ម មានកម្មករចំនួន ៥៨៤នាក់ ស្រី ២៧២នាក់ ក្នុងនោះកុមារអាយុក្រោម១២ឆ្នាំ ១៩៦នាក់ ស្រី ៩៤នាក់ និងមានកុមារអាយុ១៥ឆ្នាំឡើង ២៨នាក់ ស្រី ១២នាក់ កំពុងរស់នៅក្នុងសិប្បកម្ម។ ក្រុមអធិការកិច្ចពុំបានរកឃើញមានការប្រើប្រាស់ និងជួញដូរកម្លាំងពលកម្មកុមារនោះទេ និងបានធ្វើកិច្ចសន្យាហាមឃាត់ប្រើប្រាស់ពលកម្មកុមារចំនួន ១០៥គ្រួសារ និងធ្វើលិខិតធានាជាមួយម្ចាស់សិប្បកម្មទាំង ៣៥សិប្បកម្ម។ ក្រោយពីបានបញ្ចប់ការធ្វើអធិការកិច្ច មាន២៥សិប្បកម្មត្រូវបានដាក់កំហិត ឱ្យម្ចាស់សិប្បកម្មត្រូវចុះឈ្មោះបង្កើតគណនីសិប្បកម្ម ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធនឹងវិស័យការងារ LACMS របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### ក.៥. ការលើកកម្ពស់ជីវភាព

❖ **ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ**

▪ **ខេត្តសៀមរាប៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលការងារ វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ និងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប បានសហការជាមួយរដ្ឋបាល ខេត្តសៀមរាប ទីភ្នាក់ងារជាតិមុខរបរនិងការងារ រដ្ឋបាលស្រុកក្រឡាញ់ ស្រុកអង្គរជុំ ស្រុកពួក ស្រុកសូទ្រនិគម ស្រុកជីក្រែង និងក្រុមហ៊ុនវិស័យឯកជន បានចុះយុទ្ធនាការរៀបចំវេទិកាការងារ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់យុវជនក្រុមគោលដៅ និងពលករដែលទើបវិលត្រឡប់មកពីប្រទេសថៃ ចំនួន ២៨លើក មានអ្នកចូលរួមចំនួន ៧.៧៣០នាក់ ស្រី ៣.៩០១នាក់។ ក្នុងនោះពលករសរុប ៥.៣៥០នាក់ ស្រី ២.៥៦៤នាក់ និងអ្នកចុះឈ្មោះស្វែងរកការងារធ្វើ ចំនួន ៣.២៤២នាក់ ស្រី ១.៨៣៥នាក់។

- មជ្ឈមណ្ឌលការងារខេត្ត បានរៀបចំពិព័រណ៍ការងារចល័ត ៦លើក មានប្រជាពលរដ្ឋចូលរួមចំនួន ២.៧៥៨នាក់ ស្រី ១.៦៩៧នាក់។ បានរៀបចំវេទិកាការងារ ២លើក អ្នកចូលរួម ៩០០នាក់ ស្រី៥០០នាក់។ បានរៀបចំសិក្ខាសាលានៅតាមគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងសកលវិទ្យាល័យ ៣លើក អ្នកចូលរួម ១៥០នាក់ ស្រី៧៤នាក់។ បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព ៣៧៩កន្លែង និងបានទំនាក់ទំនង និងទទួលជួបជាមួយនិយោជក សហគ្រាស គ្រឹះស្ថាន ៣៧។ បានទទួលអ្នកចុះឈ្មោះស្វែងរកការងារធ្វើ ២.៧៧២នាក់ ស្រី ១.៩៥៩នាក់ (អតីតពលករ ២.២៧៣នាក់ ស្រី ១.៣៣៥នាក់)។ បានធ្វើការផ្គត់ផ្គង់

និងបញ្ជូនអ្នកស្វែងរកការងារធ្វើ ២.៥៩៩នាក់ ស្រី ១.០៥១នាក់ (ពលករ ២.០៣៦នាក់ ស្រី ១.១៩៧នាក់)។ អ្នកទទួលបានការងារធ្វើ ១.២០៩នាក់ ស្រី ៧៣៤នាក់ (ពលករ ៧.៩៦៤នាក់ ស្រី ៥៦៥នាក់)។ បានផ្តល់ការប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ ១.០៨៣នាក់ ស្រី ៧២៤នាក់។ អ្នកទទួលបានកម្មសិក្សា ១១នាក់ ស្រី ០៤នាក់។ អ្នកទទួលបានព័ត៌មានទីផ្សារការងារតាមរយៈខិត្តប័ណ្ណ/កម្មវិធី ៥.២០០នាក់។

- វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន សៀមរាប បានផ្សព្វផ្សាយអំពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជ្រើសរើសសិស្សចូលរៀន ក្នុងកម្មវិធីពិព័រណ៌ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ វេទិកាផ្សព្វផ្សាយពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត ១១លើក អ្នកចូលរួមចំនួន ៦.១៥៣ នាក់ ស្រី ២.៦២៤នាក់។

▪ ខេត្តប៉ៃលិន

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋានតាមភូមិ-ឃុំ - សង្កាត់ ផ្សព្វផ្សាយ និងជួយស្វែងរកការងារជូនបងប្អូនពលករខ្មែរ ដែលបានវិលត្រលប់មកពីប្រទេសថៃ បានចំនួន ៥៦២នាក់ ស្រី ២៤៧នាក់។

- ក្រុមការងារបានចុះស្រង់ស្ថិតិតាមសហគ្រាស គ្រឹះស្ថាន ដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតក្នុងខេត្ត និងបានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងពលករ ពីតម្រូវការការងារ ក្នុងសហគ្រាស គ្រឹះស្ថាន សរុបចំនួន ១.៣៣២នាក់ ស្រី ៨២៣នាក់។

▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយអាជ្ញាធរ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ប.ស.ស និងវិទ្យាស្ថានពហុបច្ចេកទេសខេត្ត ចុះផ្សព្វផ្សាយ និងចុះឈ្មោះពលករខ្មែររកការងារធ្វើសរុបចំនួន ៤.៤៧៥នាក់ ស្រី ១.៩៩៦នាក់ ក្នុងនោះអ្នកមានការងារធ្វើ និងប្រកបមុខរបរដោយផ្ទាល់ខ្លួន ៣.១៦៣នាក់ ស្រី ១.៤០២នាក់ និងមានពលករ ១៩០នាក់ ស្រី ១១០នាក់ បានចុះឈ្មោះចូលរៀនជំនាញបច្ចេកទេសវិជ្ជាជីវៈ។

❖ **ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត**

▪ **ខេត្តកំពង់ស្ពឺ៖** មន្ទីរអភិវឌ្ឍន៍ជនបទ បើកវគ្គបណ្តុះបណ្តាល ស្តីពីការចិញ្ចឹមត្រី ធ្វើជីកំប៉ុស្ត ដើម្បីបង្កើនជីវភាព និងចំណេះដឹងជំនាញនៅក្នុងគ្រួសារ ដល់ប្រជាពលពលរដ្ឋចំនួន ០៧វគ្គ អ្នកចូលរួមចំនួន ១៤០នាក់ ស្រី ៤៤នាក់។

## ២. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ២.១. ការខារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ១៧៣ករណី (ប្រៀបធៀបនឹងឆមាសទី២ ឆ្នាំ២០២៤ មានចំនួន ៩២ករណី កើនឡើង ៨១ករណី) ស្មើនឹង៨៨,០៤% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន ២៨០/១២៧នាក់ ស្រី ៣០នាក់ ជនបរទេស ២៩នាក់ (ចិន ២០នាក់ វៀតណាម ៤នាក់ ថៃ ៤នាក់ ម៉ាឡេស៊ី ១នាក់)។
- សង្គ្រោះជនរងគ្រោះចំនួន ៧១៦/២២៨នាក់ ស្រី ៤១១នាក់ មានអាយុក្រោម១៥ឆ្នាំ ៧៥នាក់ ស្រី ៦១នាក់ អាយុ១៥-១៧ឆ្នាំ ៨៤នាក់ ស្រី៧២នាក់ និងអាយុ១៨ឆ្នាំឡើង ៥៥៧នាក់ ស្រី២៧៨នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៨២នាក់ គ្រួសារ ៥៣៤នាក់)។ ក្នុងនោះចែកជា៖

## ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១០១/២៩ករណី (កើនឡើង ៧២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៧២/៥០នាក់ ស្រី១១នាក់ ជនបរទេស ១០នាក់(ចិន ៦នាក់ ថៃ ៤នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៥២៨/៩២នាក់ ស្រី ២២៦នាក់ អាយុ១៥-១៧ឆ្នាំ ២២នាក់ ស្រី៨នាក់ អាយុ១៥-១៧ឆ្នាំ ២៤នាក់ ស្រី១២នាក់ អាយុ១៨ឆ្នាំឡើង ៤៨២នាក់ ស្រី ២០៦នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៥២នាក់ គ្រួសារ ៤៧៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០២ | ០៣ | | ០២(១) |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០៣ | | ០២(២) |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៥៦ | ៨២ | ថៃ៤ | ៣២៧(១៥១) |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០២ | | ០១ |
| អំពើលក់ដូរមនុស្ស | ០២ | ០៦ | ចិន២ | ០៨ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ១០ | ៣០ | ចិន៤ | ២៣(៤) |
| អំពើនាំឆ្លងដែន | ០២ | ០៣ | | ០៧ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជល្មើស | ២៤ | ៤១ | | ១៥៦(៦៥) |
| *សរុប* | *១០១* | *១៧២* | *១០* | *៥២៨(២២៦)* |

## ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៧២/៦៣ករណី (កើនឡើង ៩ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១០៨/៧៧នាក់ ស្រី ១៩នាក់ ជនបរទេស ១៩នាក់(ចិន ១៤នាក់ វៀតណាម ៤នាក់ ម៉ាឡេស៊ី ១នាក់) សង្គ្រោះជនរងគ្រោះចំនួន ១៨៨/១៣៦នាក់ស្រី ១៨៥នាក់ មានអាយុក្រោម១៥ឆ្នាំ ៥៣នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ៦០នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង ៧៥នាក់ ស្រី៧២នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៣០នាក់ គ្រួសារ ៥៨នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០២ | ០៤ | វៀតណាម៤ | ០២(១) |
| ស្ថានទម្រង់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬបង្ខាំង | ០២ | ០៤ | ចិន៤ | ០២ |
| សញ្ចារកម្ម | ០២ | ០២ | | ០៨(៨) |
| ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០២ | ០៣ | ចិន២ | ២៤(២៤) |
| សញ្ចារកម្មទាក់ទងនឹងពេស្យាចាកុមារ | ១១ | ២៥ | | ៩០(៩០) |
| ការដឹកនាំគ្រឹះស្ថានពេស្យាចារ | ០១ | ០២ | ចិន២ | ០៧(៧) |
| រូបភាព និងសម្ភារៈអាសអាភាស | ០៧ | ១៨ | ចិន៦ ម៉ាឡេស៊ី១ | ០៦(៦) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០៣ | ០៣ | | ០៤ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៣១ | ៣៦ | | ៣១ |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ | | ១៤ |
| *សរុប* | *៧២* | *១០៨* | *១៩* | *១៨៨(១៨៥)* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ ក្នុងប្រទេស និងពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈ នាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងពីក្រៅប្រទេស សរុបចំនួន ១៥២នាក់ (ប្រុស៦នាក់ ស្រី១១០នាក់ កុមារា៦នាក់ កុមារី៣០នាក់)។ ក្នុងនោះមានៈ

- ក្នុងប្រទេសចំនួន ៥០នាក់ (ប្រុស៣នាក់ ស្រី៣២នាក់ កុមារា៦នាក់ កុមារី៩នាក់)
  -ជនជាតិខ្មែរ ២៥នាក់(ប្រុស១នាក់ ស្រី៩នាក់ កុមារា៦នាក់ កុមារី៩នាក់) សញ្ជារកម្ម១៩នាក់ រំលោភបំពានផ្លូវភេទ១នាក់ និងកេងកម្លាំងពលកម្ម៥នាក់។
  -ជនបរទេស ២៥នាក់(ប្រុស២នាក់ ស្រី២៣នាក់) មានជនជាតិឡាវ ១៦នាក់ វៀតណាម៤នាក់ ថៃ២នាក់ ចិន២នាក់ កូរ៉េខាងត្បូង១នាក់ (សញ្ជារកម្ម២១នាក់ កេងកម្លាំងពលកម្ម៤នាក់)។
- ក្រៅប្រទេសចំនួន ១០២នាក់(ប្រុស៣នាក់ ស្រី៧៨នាក់ កុមារី២១នាក់)
  -ប្រទេសចិន ៩៤នាក់(ស្រី៧៥នាក់ កុមារី១៩នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធម្មៈ
  -ប្រទេសថៃ ៧នាក់(ប្រុស៣នាក់ ស្រី៣នាក់ កុមារី១នាក់) កេងប្រវ័ញ្ចកម្លាំងពលកម្ម ២នាក់(ស្រី១នាក់ កុមារី១នាក់) និងបុគ្គលសង្ស័យថារងគ្រោះ ៥នាក់ ស្រី២នាក់
  -ប្រទេសមីយ៉ាន់ម៉ា ១នាក់(កុមារី) អាជីវកម្មផ្លូវភេទ។

➢ បានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញចំនួន ១៤៣នាក់ (ប្រុស៣នាក់ ស្រី១០៥នាក់ កុមារា៦នាក់ កុមារី២៩នាក់)។

### គ.២. ការផ្តល់សេវា

▪ ខេត្តព្រះសីហនុៈ មន្ទីរកិច្ចការនារី សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការម្លប់តាប៉ាង បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្តដល់កុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន ៧នាក់ ព្រមទាំងឧបត្ថម្ភថវិកាចំនួន ១០០,០០០រៀល ក្នុងមួយម្នាក់ និងសម្ភារៈប្រើប្រាស់របស់អង្គការ UNFPA។

### គ.៣. ការស្តារនីតិសម្បទា

បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទានៅមជ្ឈមណ្ឌលរបស់អង្គការដៃគូចំនួន ១៥២នាក់ (ប្រុស៦នាក់ ស្រី១១០នាក់ កុមារា៦នាក់ កុមារី៣០នាក់)។ ដូចជាៈ អង្គការការីតាសកម្ពុជា ៤០នាក់ អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ៤២នាក់ អង្គការរតនៈអ៊ីន ដើណេសិនណល ២៦នាក់ អង្គការមូលនិធិហាការ ១១នាក់ អង្គការសម្ព័ន្ធចាប់ដៃ ៩នាក់ អង្គការម៉ារីស៊ី ៥នាក់ អង្គការ មេត្រីអន្តរជាតិ ៤នាក់ អង្គការ IJM ១នាក់ អង្គការដើម្បីភាពញញឹមនៃកុមារ ១នាក់ មជ្ឈមណ្ឌលស្តារនីតិសម្បទាប៉ោយប៉ែត ៦នាក់ មណ្ឌលកុមារកំព្រាភ្នំពេញ ៤នាក់ ខេត្តកណ្តាលទទួលយកទៅ ៣នាក់ និងធ្វើកិច្ចសន្យាប្រគល់ទៅគ្រួសារ ៥នាក់។

### គ.៤. ការធ្វើសមាហរណកម្មជនរងគ្រោះ

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុបចំនួន ១០៨នាក់ (ប្រុស៧នាក់ ស្រី៧៧នាក់ កុមារី២៤នាក់)។

**គ.៥. ការធ្វើមាតុភូមិនិវត្តន៍**

បានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញ ចំនួន ២១នាក់(ស្រី) រួមមាន៖ ជនជាតិវៀតណាម ៤នាក់ ឡាវ ១៦នាក់ ថៃ ១នាក់។

**ឃ.៦. ការតាមដាន**

បានតាមដានករណីជនរងគ្រោះ ចំនួន ២៦០នាក់(ប្រុស៦នាក់ ស្រី៩៣នាក់ កុមារ១៩នាក់ កុមារី ១៤២នាក់)។

**ឃ.៧. ការបិទករណី**

បានបិទករណីជនរងគ្រោះ ចំនួន ៤២នាក់(ស្រី៣៣នាក់ កុមារី៩នាក់)។

**ខ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ**

**ខ.១. លិខិតបទដ្ឋានគតិយុត្ត**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - បានប្រកាសដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពី "បទដ្ឋានអប្បបរមា ដើម្បីផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូន" សម្រាប់មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង។
  - បានប្រកាសដាក់ឱ្យប្រើប្រាស់ ផែនការជាតិ អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (NIP/GCM)
  - បានប្រកាសដាក់ឱ្យប្រើប្រាស់ សៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ
  - បានបន្តរៀបចំ និងបញ្ចប់ឯកសារក្របខ័ណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ(MEL) សម្រាប់ការតាមដាន វាយតម្លៃ ការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ និងត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

**ខ.២. កិច្ចសហប្រតិបត្តិការ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់ជាមួយ៖

- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ស្តីពីសកម្មភាពបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពាក់ព័ន្ធ នឹងការកេងប្រវ័ញ្ចកម្លាំងពលរដ្ឋក្នុងបរិបទទេសន្តរប្រវេសន៍ (២០២៥-២០២៨) និងជាមួយអង្គការម៉ារីស៊ី ស្តីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ក្រុមហ៊ុន សាស្ត្រា ឯ.ក កិច្ចសហប្រតិបត្តិការ និងការលើកកម្ពស់ប្រសិទ្ធភាពការងារផ្សព្វផ្សាយ អប់រំអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**ក.១. ការបណ្តុះបណ្តាល**

❖ **ការបណ្តុះបណ្តាលក្នុងប្រទេស**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព គ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន ៣៣វគ្គ មានសិក្ខាកាមចូលរួមចំនួន ២.០២៧នាក់ ក្នុងនោះស្ត្រី ៧១៧នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយគម្រោង JICA TRUST- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ទម្រង់របាយការណ៍ និងឧបករណ៍ប្រមូលទិន្នន័យ ស្តីពីការផ្តល់សេវាគាំពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គម្រោងការអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះ ដែលរួចពីការជួញដូរមនុស្ស» | ០១ | ៦២ | ៣៣ |
| ២ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បើកវគ្គបណ្តុះបណ្តាលស្តីពី៖<br>-តួនាទីភារកិច្ច និងរបៀបរបបការងារ ក្នុងរចនាសម្ព័ន្ធ គ.ខ.ប.ជ ខេត្តព្រៃវែង<br>-កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ចំនួន៣ខេត្ត (តាកែវ កំពង់ស្ពឺ បន្ទាយមានជ័យ)<br>-ការបញ្ជ្រាបការយល់ដឹងភាពជាអ្នកដឹកនាំ ដើម្បីការផ្លាស់ប្តូរឥរិយាបថ ដែលនាំឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ទទួលបានប្រសិទ្ធភាពខ្ពស់ និងពិនិត្យមើលបទដ្ឋានអប្បរមា ក្នុងការផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូនសម្រាប់មណ្ឌលទទួលពលករ នៅមជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត និងមណ្ឌលទទួលពលករកំរៀង | ០៦ | ៤៩៧ | ១៩៤ |
| ៣ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសហការជាមួយនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល អង្គការមេត្រីអន្តរជាតិ និងការអង្គការម៉ារីស៊ី បើកវគ្គបណ្តុះបណ្តាលស្តីពី៖<br>-តួនាទីភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ឧត្តរមានជ័យ និងខេត្តសៀមរាប<br>-នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្សគ្រប់ទម្រង់ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅខេត្តកំពង់ចាម<br>-ការយល់ដឹងអំពីអំពើជួញដូរមនុស្ស ច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធ និងកិច្ចការពារកុមារនៅសហគមន៍ នៅខណ្ឌដង្កោ | ០៤ | ៦៧៥ | ១៤៧ |
| ៤ | **ខេត្តបាត់ដំបង** ស្តីពីការចែករំលែកព័ត៌មានពីអាជ្ញាធរមូលដ្ឋាន អង្គការ ស្ថាប័នពាក់ព័ន្ធដែលជាអ្នកផ្តល់សេវា ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្ត និងផលវិជ្ជមាន ពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព | ០១ | ៣៩ | ២០ |
| ៥ | **ខេត្តសៀមរាប** បានសហការជាមួយ អង្គការ CWCC អង្គការជីវិតនៅកម្ពុជា អង្គការសម្ព័ន្ធចាប់ដៃ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បើកវគ្គបណ្តុះបណ្តាល<br>-ពង្រឹងសមត្ថភាព ដល់មន្ត្រីក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង/ស្រុក ឃុំ/សង្កាត់ លើការអនុវត្តច្បាប់ ស្តីពីការអនុវត្តតួនាទីភារកិច្ច ច្បាប់គោលនយោបាយពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពាននានា ក្នុងក្រុងរុនតាឯកតេជោសែន ស្រុកវ៉ារិន ស្រុកបន្ទាយស្រី និងស្រុកជីក្រែង<br>-ការងារស្ម័គ្រចិត្ត ដល់យុវជននៅ នៃវិទ្យាល័យហ៊ុន សែន រុនតាឯក វិទ្យាល័យ វិទ្យាល័យ២៨មករា ដើម្បីចូលរួមបង្ការទប់ស្កាត់ និងជំរុញឱ្យមានការចូលរួម | ០៨ | ៣៨៤ | ១៨០ |

| | | | | |
|---|---|---|---|---|
| | អប់រំផ្សព្វផ្សាយបន្តនៅក្នុងសាលារៀន និងសហគមន៍ អំពីបញ្ហានៃអំពើជួញដូរមនុស្ស ការរំលោភបំពាននានា ពិសេសការរំលោភបំពានតាមប្រព័ន្ធអនឡាញ<br>-ពង្រឹងសមត្ថភាពសមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ខេត្ត ស្តីពីការអនុវត្តតួនាទី ភារកិច្ច ការរៀបចំរបាយការណ៍ និងការគ្រប់គ្រងស្ថិតិពលករចំណាក-ចំណូលស្រុក<br>-ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិធីសារប៉ាឡឺម៉ូ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | | | |
| | **ខេត្តកណ្តាល** បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងសេវាគាំទ្រ | ០១ | ១២៥ | ៥១ |
| ៦ | **ខេត្តព្រៃវែង**ស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំការបណ្តុះបណ្តាល ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | ០១ | ០៩ | ០៩ |
| ៧ | **ខេត្តព្រះសីហនុ** បានសហការជាមួយអង្គការ APLE បើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ | ០១ | ៤១ | ១២ |
| ៨ | **ខេត្តកំពង់ស្ពឺ** មន្ទីរកសិកម្មរុក្ខប្រម៉ាញ់និងនេសាទ បើកវគ្គបណ្តុះបណ្តាល ស្តីពីការចុះផ្សាយនិងបណ្តុះបណ្តាល បច្ចេកទេសគាំទ្រកសិកម្ម | ០៩ | ២៣៥ | ៧១ |
| | សរុប | ៣៣វគ្គ | ២.០២៧នាក់ | ៧១៧នាក់ |

❖ **ការបណ្តុះបណ្តាលនៅក្រៅប្រទេស**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិះ** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់មន្ត្រីនគរបាលជាន់ខ្ពស់ចំនួន **១០រូប** ទៅចូលរួមសិក្សា វគ្គបណ្តុះបណ្តាលប្រឆាំងការជួញដូរមនុស្ស (TIP) នៅមហាវិទ្យាល័យប៉ូលិសជាំស៊ី ទីក្រុងណានឆាង នៃសាធារណរដ្ឋប្រជាមានិតចិន ១លើក។

▪ លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមកម្មវិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីឧត្តមភាពមេដឹកនាំ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់អាស៊ាន (CTIP LEAP) នាទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ១លើក ដោយមានការឧបត្ថម្ភ និងគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី អង្គការអាស៊ានអ៊ាក់។

▪ **ខេត្តសៀមរាបះ** តំណាងវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ បានទៅចូលរួមវគ្គបណ្តុះបណ្តាលរំលឹកស្តីពី "ទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព" នៅសាធារណរដ្ឋប្រជាមានិតចិន ១លើក។

### ក.២. សិក្ខាសាលា

❖ **សិក្ខាសាលានៅក្នុងប្រទេស**

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការ JICA អង្គការសម្ព័ន្ធចាប់ដៃ អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងអនាម័យ អង្គការមូលនិធិហាការអន្តរជាតិ អង្គការដៃកម្ពុជា និងអង្គការជីវិតនៅកម្ពុជា រៀបចំសិក្ខាសាលាដើម្បីពិគ្រោះយោបល់ និងផ្សព្វផ្សាយពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) បានចំនួន **១២លើក** មានសិក្ខាកាមចូលរួមចំនួន **១.០២២នាក់** ក្នុងនោះស្ត្រី **៤០៨នាក់** ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពសិក្ខាសាលា | ចំនួនលើក | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>-ស្តីពី«ការធ្វើបច្ចុប្បន្នភាពបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល»<br>-ផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាលល្បង នូវគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប | ០២ | ១០៨ | ៥១ |
| ២ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានរៀបចំសិក្ខាសាលា៖<br>-ស្តីពីកិច្ចពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ ក្នុងការលើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តនីតិវិធីសំណងរដ្ឋប្បវេណី<br>-ស្តីពីការជំរុញការអនុវត្តយុទ្ធសាស្ត្រ បង្ការទប់ ស្កាត់អំពើជួញដូរមនុស្ស ដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន<br>-ស្តីពីការប៉ាន់ប្រមាណអំពីគុណភាព និងប្រសិទ្ធភាពនៃគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន៤ខេត្ត(ត្បូងឃ្មុំ ក្រចេះ កំពង់ចាម ខេត្តស្ទឹងត្រែង)<br>-ស្តីពីកិច្ចពិគ្រោះយោបល់លើកម្មវិធី ការផ្តល់ភាពអង់អាច ការស្តារឡើងវិញជនរងគ្រោះ និងការបង្ការទប់ស្កាត់ តាមរយៈការថែទាំពេញលេញ និងពង្រឹងប្រព័ន្ធសេវាសង្គម | ០៧ | ៦៤៩ | ២៩២ |
| ៣ | **ខេត្តសៀមរាប** ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីដំណើរការរឿងក្តីនៃអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលយុត្តធម៌ មន្ត្រីសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល | ០១ | ២០៣ | ៣៦ |
| ៤ | **ខេត្តព្រៃវែង** ប្រកាសផ្សព្វផ្សាយ ដំណើរការអនុវត្តគម្រោង (សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញដំណាក់កាលទី២) ឆ្នាំ២០២៥ | ០១ | ៦២ | ២៩ |
| | **សរុប** | **១២លើក** | **១.០២២នាក់** | **៤០៨នាក់** |

❖ **ការចូលរួមសិក្ខាសាលាក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចាត់បញ្ជូន៖

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង និងជាមន្ត្រីបច្ចេកទេសទទួលបន្ទុកការងារ COMMIT ទៅចូលរួមសិក្ខាសាលា ស្តីពី REGIONAL VALIDATION WORKSHOP ON THE SUGGESTED LIST OF COMMON INDICATORS ON TRAFFICKING IN PERSONS ( TIP ) FOR THE PURPOSE OF FORCED CRIMINALITY FACILITATED BY ABUSE OF TECHNOLOGY នៅសាធារណរដ្ឋសង្គមនិយមវៀតណាម មានបណ្តាប្រទេសជាសមាជិក COMMT (កម្ពុជា ចិន ឡាវ ភូមា ថៃ វៀតណាម)។

- ឯកឧត្តម ឧត្តមសេនីយ៍ទោ តៃ សុថារេត អគ្គលេខាធិការរង បានអញ្ជើញទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី "ដំណោះស្រាយបញ្ហា ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី តាមរយៈយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ប្រកបដោយប្រសិទ្ធិភាព បង្ការទប់ ស្កាត់ការជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងដែន ក្នុងរដ្ឋសមាជិកនៃ Bali Process" នៅប្រទេសឥណ្ឌូនេស៊ី រៀបចំដោយការិយាល័យ គាំទ្រថ្នាក់តំបន់នៃ Bali Process (Regional Support Office: RSO) មានប្រទេសអូស្ត្រាលី និងប្រទេសឥណ្ឌូនេស៊ី។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំកិច្ចប្រជុំចំនួន ០៣លើក អ្នកចូលរួមចំនួន ៧៩នាក់ ស្រី ៣៣នាក់៖ -កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួមលើកទី៣គម្រោង TRUST ការអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស។ -កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ការធ្វើបច្ចុប្បន្នភាពលើកគោលការណ៍ណែនាំ ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របលើកទី៦។ -កិច្ចប្រជុំវគ្គបណ្តុះបណ្តាល គ្រូបង្គោលលើសៀវភៅណែនាំ ស្តីពីនីតិប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំចំនួន ២៧លើក អ្នកចូលរួមចំនួន ៥៥៩នាក់ ស្រី ១៨៥នាក់ ក្នុងនោះមាន៖

- កិច្ចប្រជុំត្រួតពិនិត្យ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៩ខែ ឆ្នាំ២០២៥ ចំនួន ១លើក របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដោយមសមាសភាពចូលរួមចំនួន ៩៥នាក់ ស្រី ៣០នាក់ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ JICA ២លើក ដើម្បីពិនិត្យលើការកែសម្រួលគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប អ្នកចូលរួមចំនួន ២៤នាក់ ស្រី ១១នាក់។

- កិច្ចប្រជុំ ស្តីពីការកែសម្រួលខ្លឹមសារ ពិភាក្សាផ្តល់យោបល់ពីអនុស្សរណៈនៃការយោគយល់ រវាងអង្គការពារកុមារនៃអង្គការមូលនិធិកុមារជាតិ (CPU) និងក្រសួងមហាផ្ទៃសម្រាប់រយៈពេល៦ឆ្នាំ ១លើក អ្នកចូលរួមចំនួន ២១នាក់ ស្រី ០៣នាក់។

- កិច្ចប្រជុំជាមួយក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យលើទម្រង់ និងខ្លឹមសារ អនុសារណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃ និងអង្គការ IJM សមាសភាពមាន គ.ជ.ប.ជ ក្រុមប្រឹក្សានីតិកម្ម អង្គការ IJM សរុបចំនួន ១៤នាក់ ស្រី ២នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំជាមួយអង្គការ ម៉ារីស៊ី អង្គការ IJM អង្គការ CPU អង្គការ CWCC និងអង្គការHAGA ត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ១លើក អ្នកចូលរួមចំនួន ២០នាក់ ស្រី ០៨នាក់។

- កិច្ចប្រជុំអន្តរក្រសួង ៦លើក ស្តីពីការត្រៀមកិច្ចពិភាក្សាពហុភាគីក្នុងតំបន់ ក្នុងការឆ្លើយទៅនឹងបទល្មើសជួញដូរមនុស្សឆ្លង ដែនពាក់ព័ន្ធនឹងបទល្មើសឆបោកតាមអនឡាញ ជាមួយតំណាងទូត នៃប្រទេសឡាវ, មីយ៉ាន់ម៉ា, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលកម្ពុជាគ្រោងនឹងធ្វើជាម្ចាស់ផ្ទះ។ -កិច្ចប្រជុំពិភាក្សា ដើម្បីពិនិត្យខ្លឹមសារសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ រវាងគ.ជ.ប.ជ និងអង្គការមូលនិធិកុមារកម្ពុជា (CPU)។ -កិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីត្រៀមរៀបចំសិក្ខាសាលា ស្តីពីការជំរុញការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយការចំណាកស្រុកដោយប្រថុយប្រថាន។ -កិច្ចប្រជុំត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ២លើក។ -កិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥។

- កិច្ចប្រជុំផ្ទៃក្នុង ១៥លើក ស្តីពីការត្រៀមរៀបចំកម្មវិធីទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥។ -ពិនិត្យឆ្លងផែនការសកម្មភាព ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ -កែសម្រួលអនុស្សរណៈនៃការយោគយល់ រវាងគ.ជ.ប.ជ និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។ -ការអនុវត្តការងារប្រចាំថ្ងៃ លើតួនាទី ភារកិច្ចរបស់កងកម្លាំងនគរបាលគ្រប់ឋានានុក្រម នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

-ការរៀបចំរចនាសម្ព័ន្ធ អនុសាខា និងបណ្ដាញ នៃគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងមហាផ្ទៃ។ -ពិនិត្យ និងបំពេញបន្ថែមសេចក្ដីព្រាងរបាយការណ៍ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។ -ត្រៀមរៀបចំ សិក្ខាសាលា ពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពី "ការជំរុញការអនុវត្តយុទ្ធសាស្ត្រ បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដែល ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន"។ -ផ្សព្វផ្សាយខ្លឹមសារ នៃកិច្ចប្រជុំ ជាមួយ ឯកឧត្ដមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពីបញ្ហាជួញដូរមនុស្សតាមអនឡាញ និងការវាយតម្លៃចំណាត់ថ្នាក់ការជួញដូរមនុស្សនៅកម្ពុជា ឆ្នាំ២០២៥។ -ត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥។

▪ **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប, កណ្ដាល, កំពង់ចាម, ព្រះវិហារ, ព្រៃវែង, ខេត្តរតនគិរី** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែកក្កដា ខែសីហា ខែកញ្ញា តុលា វិច្ឆិកា ធ្នូ ត្រីមាសទី២ ត្រីមាសទី៣ ឆមាសទី១ និងឆ្នាំ២០២៥ សរុបចំនួន ១៩លើក អ្នកចូលរួមចំនួន ២.១៥៤នាក់ ស្រី ៦៧៦នាក់។

❖ **ការចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់តំបន់លើកទី៣ នៃគណៈកម្មាធិការជាតិអាស៊ីអាគ្នេយ៍ប្រឆាំងការ ជួញដូរមនុស្ស ដែលភាគីកម្ពុជា មានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅហ្វីលីពីន លេខាទី២ នៃស្ថានទូតកម្ពុជាប្រចាំនៅ ហ្វីលីពីន និងប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ រៀបចំឡើងដោយ ក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញ ដូរមនុស្ស ហ្វីលីពីន (IACAT) នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។

- បានដឹកនាំប្រតិភូក្រុមការងារខមមីតកម្ពុជា ចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់លើកទី៦ (IMM6) បន្ទាប់ពីក្រុមការងារបច្ចេកទេសអន្តរក្រសួង (RTF) នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយម វៀតណាម។ ជាលទ្ធផល គឺបានអនុម័ត ផែនការជំហានទី៥ (SPA V) ២០២៥-២០៣៥ អនុម័តសេចក្ដីថ្លែង ការណ៍រួម និងទិសដៅ ក្នុងការធ្វើឱ្យសកម្មភាពប្រឆាំងការជួញដូរមនុស្ស មាននិរន្តរភាព តំណាងប្រទេសទាំង៦ រដ្ឋមន្ត្រីមីយ៉ាន់ម៉ា អនុរដ្ឋមន្ត្រីចិន អនុរដ្ឋមន្ត្រីឡាវ អនុរដ្ឋលេខាធិការថៃ រដ្ឋលេខាធិការកម្ពុជា អនុរដ្ឋមន្ត្រីវៀតណាម។

▪ **អគ្គលេខាធិការដ្ឋាន** គ.ជ.ប.ជ បានចាត់បញ្ជូនៈ

១).លោកជំទាវ ឧត្ដមសេនីយ៍ទោ វ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង ទៅចូលរួមប្រជុំនៅទីក្រុងម៉ាឡាកា ប្រទេសម៉ាឡេស៊ី

- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន SOMTC ត្រៀមសម្រាប់ AMMTC លើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ លោកជំទាវ **វីរក្ស វិជ្ជតា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តំណាងប្រធាន SOMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស រួមទាំងទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ សរុបចំនួន **១៨០រូប**។

- បើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៩(AMMTC) និងកិច្ចប្រជុំ ពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្ដម នាយឧត្ដមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និងប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ សរុបចំនួន **៥០០រូប**។

- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១ (AMMTC) និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្ដម នាយឧត្ដមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្ដម អភិសន្តិ បណ្ឌិត **ស សុខា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន AMMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និង ប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ ចំនួន **២៣០រូប**។

២).ឯកឧត្តមសេនីយ៍ទោ តែ សុថារេត អគ្គលេខាធិការរង គ.ជ.ប.ជ ទៅចូលរួមកិច្ចប្រជុំ "Regional Consultation Workshops on Strengthening the Non-Punishment Principle in Trafficking in Persons Cases of Forced Criminality" នៅប្រទេសឥណ្ឌូនេស៊ី ១លើក។

៣).លោកស្រីវរសេនីយ៍ឯក ថោង សុវត្ថិ ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ ទៅចូលរួមកិច្ចសន្ទនាសិទ្ធិមនុស្សអាស៊ានលើកទី៧ និងពិធីប្រារព្ធខួបសេចក្ដីប្រកាសសិទ្ធិមនុស្សអាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី ១លើក។

**ខ.២. ទស្សនកិច្ច**

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានដឹកនាំគណៈប្រតិភូម្ចាស់ជំនួយនៃអង្គការការីតាសស្វីស ប្រចាំនៅកម្ពុជា ធ្វើទស្សនកិច្ចនៅមណ្ឌលទទួលពលករកំរៀង ច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ច្រកទ្វារអន្តរជាតិភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង និងបានជួបសំណេះសំណាល ជាមួយពលករ ដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃ។

- បានធ្វើទស្សនកិច្ចនៅមណ្ឌលថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស (TIP Center) ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញដូរមនុស្ស ហ្វីលីពីន (IACAT) នៅប្រទេសហ្វីលីពីន។

**ខ.៣. ជំនួបពិភាក្សាការងារ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ថ្នាក់ដឹកនាំ និងក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយៈ

- លោកស្រី គ្រីស្ទីន ប៉ាកកូ នាយិកាប្រតិបត្តិអង្គការទេសន្តប្រវេសន៍អន្តរជាតិ ប្រចាំនៅប្រទេសស្រីលង្កា ដើម្បីពិភាក្សាការងារត្រៀមរៀបចំទស្សនៈកិច្ច របស់គណៈប្រតិភូស្រីលង្កា

- គណៈប្រតិភូប្រទេសស្រីលង្កា ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមក លើការងារពាក់ព័ន្ធនឹងកតិកាសញ្ញាពិភពលោក GCM

- ប្រតិភូនៃអង្គការទេសន្តប្រវេសន៍អន្តរជាតិ ដឹកនាំដោយលោកស្រី Nellie Ghusayni ប្រធានបេសកកម្ម នៃអង្គការ IOM ប្រចាំនៅកម្ពុជា ស្ដីពីការស្វែងរកកិច្ចសហការបន្ថែម រវាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមរដ្ឋជ័យលាភីនៃការអនុវត្តកាតិកាសញ្ញាពិភពលោក ស្ដីពីចំណាកស្រុកដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (GCM)

- គណៈប្រតិភូប្រទេសបង់ក្លាដេស ដែលមកបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសកម្ពុជា ជួបសម្ដែងការគួរសម និងចែករំលែកបទពិសោធន៍ អំពីកិច្ចខិតខំប្រឹងប្រែងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- តំណាងអង្គការ AusCam ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- និងបានដឹកនាំប្រតិភូគណៈកម្មការសាខាសមាគមនារីក្រសួងមហាផ្ទៃ ទទួលជួបតំណាងក្រុមហ៊ុន YHS Cambodia ដឹកនាំដោយ លោកស្រី ហេង សុទ្ធាវី អគ្គនាយិកា ដើម្បីពិនិត្យ និងពិភាក្សាការងារសម្រាប់កិច្ចសហការក្នុងការអនុវត្តសកម្មភាពមនុស្សធម៌ និងការងារសង្គម របស់សមាគមនារីក្រសួងមហាផ្ទៃ។ និងជាមួយតំណាងអង្គការសម្ព័ន្ធចាប់ដៃ ផ្ដល់ការណែនាំសម្រាប់ការរៀបចំសិក្ខាសាលា ស្ដីពី «កិច្ចពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ ក្នុងការលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តនីតិវិធីសំណាងរដ្ឋប្បវេណី»។

▪ **ខេត្តសៀមរាប** បានទទួលជួបពិភាក្សាការងារជាមួយៈ -អង្គការសម្ព័ន្ធចាប់ដៃ ស្ដីពីការអនុវត្តសកម្មភាពរួមគ្នារវាងគណៈកម្មាធិការគ.ខ.ប.ជខេត្ត និងអង្គការ។ -អង្គការអេ២១ ស្ដីពីការផ្ដល់សេវា ដល់ករណីរំលោភបំពាន តាមអនឡាញ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម, ការរៀបចំវេទិកាសាធារណៈ ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។ -អង្គការទស្សនៈពិភពលោក ស្ដីពីយន្តការនៃការរាយការណ៍ និងការបញ្ជូននៅសហគមន៍ ដើម្បីចុះផ្សព្វផ្សាយបន្តតាមឃុំ។ -អង្គការក្លែនអន្តរជាតិ អំពីស្ថានភាពទូទៅរបស់គ្រួសារ ពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ។ -អង្គការ ILO ស្ដីពីកិច្ចគាំពារផ្នែកច្បាប់ដល់ពលករលើទូកនេសាទ។

▪ ខេត្តកំពង់ចាម បានជួបពិភាក្សាការងារ និងប្រជុំជាមួយអង្គការ IJM ដើម្បីសម្ពោធគម្រោងពង្រឹងសមត្ថភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដើម្បីការពារពលករក្នុងបរិបទទេសន្តរប្រវេសន៍។

▪ ខេត្តក្រចេះ បានទទួលជួបពិភាក្សាការងារ ជាមួយអង្គការសកម្មភាពដើម្បីកុមារ ដើម្បីប្រមូលទិន្នន័យ និងលទ្ធផលគម្រោងរយៈពេល០៣ឆ្នាំ (២០២៣-២០២៥) របស់អង្គការ។

### គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន **១១២**លើក។ (**ឧបសម្ព័ន្ធ**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា

- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

### គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូងដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ដ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅឆមាសទី១ ឆ្នាំ ២០២៦

ដើម្បីពង្រឹងបន្ថែមនូវកិច្ចខិតខំប្រឹងប្រែង ដែលនៅតែប្រឈមនឹងការវាយតម្លៃ មិនទាន់បានល្អប្រសើរនៅឡើយ និងដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាព តាមយុទ្ធសាស្ត្រទាំងបួនដែលបានកំណត់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាដើម្បីពង្រឹងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមដាក់ចេញនូវ ទិសដៅដើម្បីអនុវត្តបន្ត ដូចខាងក្រោម៖

១.បន្តពង្រឹងកិច្ចសហការទូលំទូលាយជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន បន្តអនុវត្តវិធានការបង្ការទប់ស្កាត់ ដែលឈានដល់ការផ្លាស់ប្តូរឥរិយាបថ តាមរយៈការជួបប្រជុំពិភាក្សាជាក្រុមនៃវិស័យពាក់ព័ន្ធ បង្កើតសកម្មភាពរួមគ្នា ដែលបង្កើនភាពជឿជាក់ពីប្រជាពលរដ្ឋ ជាពិសេស ក្រុមជនទេសន្តប្រវេសន៍ដែលវិលត្រឡប់ពីប្រទេសថៃ និងក្រុមប្រជាជន ដែលភៀសសឹក និងបែងចែកភារកិច្ច ពង្រាយបណ្តាញ ជាកម្លាំង ឆ្ពោះទៅកាន់តំបន់គោលដៅជាអាទិភាព

២.ត្រៀមប្រកាស ឯកសារ ស្តីពីការតាមដាន វាយតម្លៃ និងសិក្សា (MEL) ដើម្បីអនុវត្តក្នុងការវាយតម្លៃផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៣.ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែក ការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេស ពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៤.គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៥.ចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំកំពូល ដើម្បីពង្រឹងកិច្ចសហការ ក្នុងមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំផ្សេងៗ ថ្នាក់តំបន់ និងជាអន្តរជាតិ

៦.បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព ការបញ្ជ្រាបតាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព កម្មវិធីបុណ្យជាតិ ការរៀបចំយុទ្ធនាការទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងប្រើគ្រប់លទ្ធភាព ធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេស ស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៧.បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៨.ជំរុញតាមដានត្រួតពិនិត្យ ក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៩.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

១០.ជំរុញការអនុវត្តគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ ដើម្បីផ្តល់សេវាសមស្របដែលជានិយាមមិនអាចខ្វះបាន ក្នុងការអនុវត្ត

១១.ចូលរួមដោះស្រាយបញ្ហានៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម

១២.បន្តដោះស្រាយ ឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីរកប្រាក់ចំណូល តាមវិធីសាស្ត្រ ជំនាញនៃវិស័យពាក់ព័ន្ធដល់ប្រជាពលរដ្ឋ ជាពិសេស ជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក៕

ថ្ងៃ..................ខែ.............. ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ............ឆ្នាំ២០២...

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ការងារសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលផ្កាឈូក អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា។ និងពិធីប្រកាសដាក់ឱ្យអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
  - ពិធីសំណេះសំណាល និងផ្សព្វផ្សាយពីភារកិច្ចចំពោះមុខ របស់សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅវិមាន៧មករា រាជធានីភ្នំពេញ
  - អមអធិបតី ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងឱកាសជួបប្រជុំជាមួយឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រ ក្នុងការផ្សព្វផ្សាយអំពីឱកាសការងារ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំក្រុមការងារ សម្របសម្រួលជូនប្រជាពលរដ្ឋជម្លៀសខ្លួន ពីតំបន់ព្រំដែន និងពលករកម្ពុជាដែលវិលត្រឡប់មកពីប្រទេសថៃ។ កិច្ចប្រជុំស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត របស់ក្រុមការងារត្រួតពិនិត្យឡើងវិញ (RPG) ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ។ កិច្ចប្រជុំចង្អៀត ស្តីពីការដាក់ចំណាត់ថ្នាក់កម្ពុជាដោយក្រសួងការបរទេសសហរដ្ឋអាម៉េរិច ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំត្រួតពិនិត្យ របាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៩ខែ ឆ្នាំ២០២៥។ ពិធីផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងទង់នគរបាលជាតិកម្ពុជា។ កិច្ចពិភាក្សាលើការងារកំណែទម្រង់ តម្រង់ទិស និងពង្រឹងការងារវិស័យសន្តិសុខ នៃកងកម្លាំងនគរបាលជាតិ។ កិច្ចប្រជុំ ដោះស្រាយបណ្តឹងអន្តរាគមន៍ ជនរងគ្រោះជាជនបរទេស ករណីឆបោកអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - ជាគណអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពប្រចាំឆមាសទី១ ឆ្នាំ២០២៥ នៅសាលាខេត្តកំពង់ឆ្នាំង
  - កិច្ចប្រជុំឆ្លងសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីចលនាប្រឡងប្រណាំងចំពោះបុគ្គលដែលមានស្នាដៃឆ្នើម ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព
  - កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅសណ្ឋាគារ រ៉េស៊ីដង់សុខាភ្នំពេញ
  - កិច្ចប្រជុំស្តាប់ការធ្វើបទបង្ហាញ ស្តីពីការអភិវឌ្ឍន៍ និងការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ
  - រួមដំណើរជាមួយ ឯកឧត្តម តេង សួន អនុរដ្ឋលេខាធិការ ឯកឧត្តម ហែម ថេង អនុរដ្ឋលេខាធិការ ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះបំពេញបេសកកម្មការងារ នៅខេត្តបន្ទាយមានជ័យ ដើម្បីសហការជាមួយអាជ្ញាធរខេត្ត និងស្ថាប័នពាក់ព័ន្ធ ជួយសម្របសម្រួលដល់ពលករខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ នៅច្រកអន្តរជាតិប៉ោយប៉ែត
  - ដឹកនាំក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះត្រួតពិនិត្យទីតាំងត្រៀមរៀបចំកម្មវិធី «ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៩» ឆ្នាំ២០២៥ ឱ្យបានល្អប្រសើរ នៅមជ្ឈមណ្ឌលសន្និបាត និងពិពណ៌អន្តរជាតិជ្រោយចង្វារ។
  - កិច្ចប្រជុំបច្ចុប្បន្នភាពស្ថានភាពជម្លោះព្រំដែនកម្ពុជា-ថៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ
  - ដឹកនាំកិច្ចប្រជុំក្រុមការងារពិធីការ ក្រុមាការងារសន្តិសុខ និងតំណាងសាសនានានា ដើម្បីពិភាក្សាអំពីដំណើរការរៀបចំទិវាជាតិអន្តរសាសនាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិពណ៌អន្តរជាតិជ្រោយចង្វារ
  - ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមកិច្ចពិភាក្សាកម្រិតថ្នាក់ដឹកនាំ ស្តីពីការរៀបចំថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ជាគណៈអធិបតី ក្នុងពិធីជួបសំណេះសំណាល ជាមួយប្រជាពលករដែលវិលត្រឡប់មកពីប្រទេសថៃ និងគ្រួសារកងទ័ពក្នុងខេត្តកំពង់ឆ្នាំង សរុប ៥៨គ្រួសារ និងគ.ជ.ប.ជ បន្ថែមជាកញ្ចប់សម្ភារៈ ១៣មុខ និងថវិកា៥០.០០០រៀល សម្រាប់គ្រួសារទាំង៥៨ និងបន្ថែមថវិកា ១០ម៉ឺនរៀល ដល់គ្រួសារទ័ព ទាំង១៩គ្រួសារ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេសប្រធានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តកំពង់ឆ្នាំង នៅសាលប្រជុំសាលាក្រុងកំពង់ឆ្នាំង
- ដឹកនាំប្រតិភូក្រសួងមហាផ្ទៃ ចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់ដើម្បីពិនិត្យ និងពិភាក្សាលើករណីគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីផ្ទេរការងារដឹកនាំ និងសម្របសម្រួលនៃក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (ក្រុមការងារខមមីតកម្ពុជា) នៅក្នុងក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី
- ជាអធិបតី វគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងចំណាកស្រុកដោយគ្មានសុវត្ថិភាព និងជម្រើសមុខរបរនិងការងារ ជូនដល់និស្សិតនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប
- ដឹកនាំកិច្ចពិភាក្សា ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារ ខមមីតថ្នាក់តំបន់ Regional Taskforce Meeting (RTF) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី Inter-Ministerial Meeting (IMM) លើកទី៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមមូលបទ "ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល" តាមរយៈប្រព័ន្ធ Zoom Meeting
- កិច្ចប្រជុំត្រីមាសទី៣ ឆ្នាំ២០២៥ របស់គម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍កម្ពុជា ជំហានទី២ ដែលរៀបចំដោយ អង្គការការីតាសស្វីស នៅសណ្ឋាគារភ្លាស់ស៊ី ខេត្តបាត់ដំបង
- ជាអធិបតីក្នុងកម្មពិធីដាក់ឱ្យប្រើប្រាស់ ផែនការយុទ្ធសាស្ត្រជាតិ កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- ជាអធិបតី ក្នុងកិច្ចប្រជុំ បូកសរុបលទ្ធផលនៃការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ប្រចាំនព្វមាស ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង
- ដឹកនាំកិច្ចពិភាក្សាលើកទី២ ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារ ខមមីតថ្នាក់តំបន់ Regional Taskforce Meeting (RTF) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី Inter-Ministerial Meeting (IMM) លើកទី៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមមូលបទ "ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល" តាមរយៈប្រព័ន្ធ Zoom Meeting ចេញពីសាលប្រជុំ គ.ជ.ប.ជ
- កិច្ចប្រជុំ ពិនិត្យ និងសម្រេចលើផែនការសកម្មភាព និងផែនការថវិកា សម្រាប់អនុវត្តគម្រោង "សុវត្ថិភាពទេសន្តរប្រវេសន៍កម្ពុជា (SaMiCa)" ជំហានទី២ ឆ្នាំ២០២៦ រៀបចំដោយអង្គការការីតាស់ស្វីស នៅសណ្ឋាគារ Capri រាជធានីភ្នំពេញ
- កិច្ចប្រជុំបច្ចេកទេស ដើម្បីផ្សព្វផ្សាយគោលការណ៍ បែបបទ នីតិវិធី និងបទប្បញ្ញត្តិ នៃការអនុវត្តប្រព័ន្ធលើកទឹកចិត្ត គាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដឹកនាំដោយ ឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ **ប៉ុណ្ណ សំខាន** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
- សិក្ខាសាលា ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការសម្អាតប្រាក់។ កិច្ចប្រជុំចង្អៀត ស្តីពីការដាក់ចំណាត់ថ្នាក់កម្ពុជាដោយក្រសួងការបរទេសសហរដ្ឋអាមេរិច ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ ពិភាក្សា និងដាក់ទិសដៅការងារសម្រាប់អនុវត្តបន្ត ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- ដឹកនាំមន្ត្រី នៃអគ្គលេខាធិការដ្ឋានចំនួន ២០រូប ដើម្បីចូលរួមពិធីផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋាន ស្តីពីបញ្ហាគ្រឿងញៀន របស់គណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម **កៅ ខុនជាវ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
- កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ពិនិត្យមាតិកាលើប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ប្រាក់ ច័ន្ទណាយ** រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដោយផ្តោតលើកស្តុតាង និងឬសក្ខីកម្មដែលបានថតទុកជាវីដេអូ ក្រោមអធិបតីភាព ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ នៅសណ្ឋាគារកាំបូឌីយ៉ាណា
- សិក្ខាសាលាប្រមូលលទ្ធផលគម្រោង (ស្រួល) ឆ្នាំទី៣ ដើម្បីបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច និងរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ
- សន្និសីទថ្នាក់តំបន់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងជំនាញ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ នៅខេត្តសៀមរាប
- ធ្វើបទបង្ហាញ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឆមាសទី១ ឆ្នាំ២០២៥ នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **សុង ធវន្ត** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលសហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅសណ្ឋាគារសាន់អែនមូន រាជធានីភ្នំពេញ
- សិក្ខាសាលា ស្តីពីតួនាទីភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវ របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងពេញលេញ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៅសណ្ឋាគារ Empress Angkor ខេត្តសៀមរាប
- ពិធីប្រកាសផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បុរី** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវតិសម្បទា
- កិច្ចប្រជុំឆ្លុះបញ្ចាំង គម្រោង PROTECT អំពីវឌ្ឍនភាព បញ្ហាប្រឈម និងវិធីឆ្ពោះទៅមុខ ក្នុងគោលបំណង គឺដើម្បីបង្កើតផែនការដាក់លាក់របស់គម្រោង និងពិចារណា ចក្ខុវិស័យជាយុទ្ធសាស្ត្រ និងទិសដៅនៃការងារសម្រាប់ឆ្នាំ២០២៦ រយៈពេល២ថ្ងៃ រៀបចំដោយអង្គការ UNICEF នៅសណ្ឋាគារសាន់អែនមូនរីវើសាយដ៍ រាជធានីភ្នំពេញ
- ពិធីដាក់ឱ្យប្រើប្រាស់ ផែនការយុទ្ធសាស្ត្រជាតិ កតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការពង្រឹងគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការជួញដូរមនុស្ស ករណីនៃឧក្រិដ្ឋកម្មដោយបង្ខំ ដែលរៀបចំរួមគ្នាដោយគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស (AICHR) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) ដោយមានការគាំទ្រពីកម្មវិធីប្រឆាំងការជួញដូរមនុស្សអាស៊ាន-អូស្ត្រាលី ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី Zoom ពីទីស្នាក់ការអង្គការ កម្មវិធីប្រឆាំងការជួញដូរអាស៊ាន-អូស្ត្រាលី (ASEAN-ACT) រាជធានីភ្នំពេញ
- កិច្ចប្រជុំពិភាក្សាលើការរៀបចំស្តង់ដារ ប្រតិបត្តិសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារ ក្នុងបរិបទទេសន្តប្រវេសន៍ រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឧបត្ថមគាំទ្រដោយអង្គការ UNICEF និងសហគមន៍ EU នៅសណ្ឋាគារ អេរ៉ា ភ្នំពេញ
- ប្រកាសដាក់ឱ្យប្រើប្រាស់ គោលការណ៍ណែនាំ ស្តីពីបទដ្ឋានអប្បបរមា ដើម្បីផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូនសម្រាប់មណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តបាត់ដំបង

- កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់តំបន់ (RPSC) មានការចូលរួមពីសមាជិក (RPSC) ទាំង៧ប្រទេស មានការសម្របសម្រួលនិងឧបត្ថមគាំទ្រពីកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) តាមរយៈកម្មវិធី Zoom ពីការិយាល័យប្រទេសកម្ពុជា នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) រាជធានីភ្នំពេញ
- ជាអធិបតីក្នុងកម្មវិធីបើក កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការសិក្សាពិធីសារបន្ថែមស្តីពីនីតិវិធីបណ្តឹង (OP3) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ អង្គការសហប្រជាជាតិ និងការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការផ្តល់សច្ចាប័នរបស់កម្ពុជា ដែលរៀបចំដោយការិយាល័យយូនីសេហ្វប្រចាំកម្ពុជា និងទីប្រឹក្សា Coram International និងមានការសម្របសម្រួលដោយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ
- ជាអធិបតីក្នុងពិធីបើក កិច្ចប្រជុំឆ្លុះបញ្ចាំងជាមួយជនបង្គោល និងអ្នកពាក់ព័ន្ធ ដើម្បីបង្ហាញលទ្ធល និងធ្វើផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦ របស់អង្គការសម្ព័ន្ធចាប់ដៃ សមាសភាពចូលរួម ៣៦នាក់ ស្រី ២៦នាក់ នៅសាលាស្រុកពញាក្រែក
- ជាសហអធិបតី ជាមួយឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ក្នុងពិធីបើក "សិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាលល្បង នូវគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" នៅខេត្តត្បូងឃ្មុំ។

- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១១៩ច្បាប់) លិខិតចូល (១១៩ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(១០១ច្បាប់)លិខិតចូល(១១៧ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - ចូលរួមសិក្ខាសាលាប្រមូលលទ្ធផលគម្រោង(ស្រួល)ឆ្នាំទី៣ រៀបចំដោយអង្គការ Terre des Hommes Netherland
  - បានចូលរួមសិក្ខាសាលាបិទគម្រោង សិទ្ធិ និងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ់(ស្រួល)
  - បានចូលរួមសិក្ខាសាលាពិគ្រោះយបល់ ស្តីពីបញ្ញសិប្បនិម្មិត និងសុវត្ថិភាពសម្រាប់កុមារ រៀបចំដោយអង្គការ ដែនដីមនុស្សហូឡង់ដ៍
  - បានចូលរួមរៀបចំពិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងចំណាកស្រុកដោយគ្មានសុវត្ថិភាព ជម្រើសមុខរបរ និងការងារ ដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាល័យ ជា ស៊ីម ឈូកវ៉ា
  - បានចូលរួមរៀបចំពិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ក្នុងវិស័យព័ត៌មានដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងព័ត៌មាន អ្នកសារព័ត៌មានជាតិ អ្នកបង្កើតមាតិកាតាមបណ្តាញព័ត៌មានសង្គមអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងព័ត៌មាន។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ចូលរួមកម្មវិធីផ្សព្វផ្សាយ ស្តីពីមូលដ្ឋានគ្រឹះនៃជម្ងឺអេដស៍ និងវិធីសាស្ត្របង្ការទប់ស្កាត់ការឆ្លងជម្ងឺដល់មន្ត្រីជំនាញ កីឡាករ និងកីឡាការិនី ក្រោមអធិបតីភាព លោកជំទាវ **អុង សុភាវី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍កាមរោគ នៅទីស្តីការក្រសួងមហាផ្ទៃ
  - ចូលរួមសិក្ខាសាលា ស្តីពីអនុសាសន៍ និងនីតិវិធីវាយតម្លៃ អញ្ញមញ្ញសកលជុំទី៥ របស់ក្រុមការងារហិរញ្ញវត្ថុ សម្រាប់អាជ្ញាធរអនុវត្តន៍ច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម **ហេង បូមករា** ប្រធានអង្គភាពស៊ើបអង្កេតហិរញ្ញវត្ថុ
  - ចូលរួមសិក្ខាសាលា គំរូសិក្សា(Typology) ប្រចាំឆ្នាំ២០២៥ របស់ប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ (APG) នៅសាលប្រជុំធានាគារជាតិកម្ពុជា
  - ចូលរួមជំនួបសំណេះសំណាល និងសម្ភាសជាមួយសិក្ខាកាម ដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹង ក្រោយពីការបណ្តុះបណ្តាលកន្លងមក ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប កិច្ចសហការ និងឧបត្ថម្ភពីអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ

- ចូលរួមសិក្ខាសាលា ស្តីពីការផ្ទៀងផ្ទាត់របាយការណ៍ សិក្សាស្រាវជ្រាវ ផលប៉ះពាល់លើពលករចំណាកស្រុកដែលត្រឡប់មកវិញ អំឡុងពេលមានជម្លោះព្រំដែន នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ
- អមដំណើរលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីសន្ទនាមតិ ជីវិតយើង សង្គមយើង ដែលត្រូវពិភាក្សាប្រធានបទ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល នៅស្ថានីយវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការសិក្សាស្រាវជ្រាវ អំពីសម្លេងយុវជន ដើម្បីបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទ និងការឆបោកកុមារ តាមប្រព័ន្ធអនឡាញ នៅសណ្ឋាគារ ពូឡូវ៉េ រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

- ចូលរួមសិក្ខាសាលាត្រីភាគី ត្រៀមថ្នាក់ជាតិសម្រាប់កម្ពុជាវេទិកាអាស៊ានលើកទី១៨ ស្តីពីទេសន្តរប្រវេសន៍ការងារ ក្រោមប្រធានបទ «ការពន្លឿនសកម្មភាពឆ្ពោះទៅមុខរកគោលដៅអភិវឌ្ឍន៍ ប្រកបដោយចិរភាព ស្តីពីការធ្វើទេសន្តរប្រវេសន៍ក្រប្រកដោយសុវត្ថិភាព និងការងារសមរម្យ សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងតំបន់អាស៊ាន» ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ី វុទ្ធី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅសណ្ឋាគារកាំបូឌីយ៉ាណា
- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទ កុមារតាមប្រព័ន្ធអនឡាញ ក្រោមការរៀបចំពីអង្គការ Auscam freedoms projeet ដែលមានក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ នៅសាលប្រជុំសាន់អេនមូន រាជធានីភ្នំពេញ
- បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃគ.ជ.ប.ជ ចុះបំពេញបេសកកម្ម ដើម្បីរៀបចំវេទិកាផ្សព្វផ្សាយ ស្តីពីការយល់ដឹងពីហានីភ័យ និងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សក្នុសហគមន៍ ក្នុងឃុំចំនួន ០៤ នៃស្រុកពារាំង និងក្នុងឃុំចំនួន ០៤ នៃស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
- ចូលរួមកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំការងារផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ សុខាភិបាល ផ្គត់ផ្គង់ និងដឹកជញ្ជូន ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
- បានចូលរួមទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ ឆ្នាំ២០២៥ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ IOM និងអង្គការ ILO នៅទីស្តីការក្រសួងការងារ
- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ឆ្នាំ២០២៥ នៅនៃទីស្តីការក្រសួងការងារ។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- ចូលកិច្ចប្រជុំពិភាក្សាដើម្បីពិនិត្យ និងរៀបចំធាតុចូល សម្រាប់សេចក្តីព្រាងសុន្ទរកថា គោរពជូន សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ថ្លែងក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅថ្ងៃទី២៦-២៨ ខែតុលា ឆ្នាំ២០២៥ ដឹកនាំដោយ ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC-កម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំរបាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) នៅទីស្តីការក្រសួងមហាផ្ទៃ
- បានរៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការយុត្តិធម៌
- បានចូលរួមសម្របសម្រួលការងាររៀបចំ ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ២០២៥ ដែលគ្រោងប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និសីទនិងពិពរណ៍កោះពេជ្រ
- បានចូលរួមសិក្ខាសាលាពង្រឹងសេវាសមាហរណកម្ម និងសម្របសម្រួលការគាំទ្រ ដល់ពលករទេសន្តរប្រវេសន៍ ដែលបានវិលត្រឡប់មកវិញ ក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារសុខាអង្គរីសត ខេត្តសៀមរាប។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដោយផ្តោតលើភស្តុតាង និងឬសក្ខីកម្មដែលបានថតទុកជាវីដេអូ ក្រោមអធិបតីភាព ឯកឧត្តម **កេង សុម៉ាវិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌

- ចូលរួមកិច្ចប្រជុំត្រួតពិនិត្យទិន្នន័យរបាយការណ៍ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។
- បានចូលរួមសិក្ខាសាលា រយៈពេល៣ថ្ងៃ អំពីគំរូសិក្សា (Typology) ប្រចាំឆ្នាំ២០២៥ របស់ប្រទេស អាស៊ីប៉ាស៊ីហ្វិក ស្តីពីការសំអាតប្រាក់(APG) នៅបន្ទប់ប្រជុំធនាគារជាតិកម្ពុជា
- ចូលរួមកិច្ចចរចា ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ២០២៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ រយៈពេល២ថ្ងៃ នៅវិមានរដ្ឋាភិបាល
- បានចូលរួមអបអរសាទរទិវាអន្តរជាតិសម្រាប់ពលករទេសន្តប្រវេសន៍ ឆ្នាំ២០២៥។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការពង្រឹងគោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងការជួញដូរមនុស្សករណីនៃឧក្រិដ្ឋកម្មដោយបង្ខំ តាមរយៈ Zoom Meeting រយៈពេល២ថ្ងៃ រៀបចំដោយ AICHR, ASEAN-ACT និង SOMTC នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី មានប្រតិភូចូលរួមមកពីប្រទេសថៃ ហ្វីលីពីន កម្ពុជា ឡាវ និងវៀតណាម
  - បានចូលរួមកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ក្រោមអធិបតីភាព លោកជំទាវ **សុង ធវន្ត** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ នៅសណ្ឋាគារសាន់អែនមូន រាជធានីភ្នំពេញ
  - បានកិច្ចប្រជុំគណៈកម្មាធិការខ្លឹមសារ ដើម្បីរៀបចំឯកសារសម្រាប់មហាសន្និបាត សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅវិមាន៧មករា
  - បានរៀបចំកិច្ចប្រជុំជាមួយក្រុមជំនួយកិច្ចការយុត្តិធម៌ ស្តីពីការរៀបផែនការ ដើម្បីរៀបចំថវិកាសម្រាប់ឆ្នាំ២០២៦
  - បានចូលរួមសិក្ខាសាលា«2025 KACPE International Pacific Policy Symposium: Advancing Together: Korea-ASEAN Strategic Alliance Toward ASEAN Vision 2045» ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុក បេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិអេស្កាប់ នៅសណ្ឋាគារ Shangri-La Phnom Penh
  - បានចូលរួមកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារ ត្រៀមរៀបចំទិវាជាតិ១២ធ្នូ របស់ក្រុមទី៣ ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ និងជាប្រធានក្រុមការងារព័ត៌មានវិទ្យា រូបភាព បទយកការណ៍ និងផ្សព្វផ្សាយ នៅសាលប្រជុំ គ.ជ.ប.ជ
  - បានដឹកនាំក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលជាសមាជិកផែនប្រឆាំងការជួញដូរមនុស្ស នៃក្រុមការងារ SOMTC-Cambodia ចូលរួមសិក្ខាសាលាអនឡាញលើកទី២ ស្តីពី Monitoring and Reporting MERL Framework of the Bohol TIP Work Plan 2.0 រៀបចំដោយ SOMTC-Philippines ក្នុងនាមជា Voluntary Lead Shepherd តាមរយៈប្រព័ន្ធប្រជុំអនឡាញ
  - បានចូលរួមជាគណៈអធិបតីក្នុង ពិធីបើកសិក្ខាសាលាពង្រឹងសេវាសមាហរណកម្ម និងសម្របសម្រួលការគាំទ្រដល់ពលករទេសន្តប្រវេសន៍ ដែលបានវិលត្រឡប់មកវិញ ក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារ សុខាអង្គររីសត ខេត្តសៀមរាប
  - ដោយទទួលបានការអនុញ្ញាតិជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ ជាតំណាង លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និង លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ បានចុះសួរសុខទុក្ខ និងនាំយកនូវកញ្ចប់សម្ភារៈ ៤០០កញ្ចប់ និងអាវ១០០ ជួយសម្រាលការលំបាករបស់ប្រជាពលរដ្ឋភៀសសឹកជាស្ត្រីមានផ្ទៃពោះ ស្ត្រី និងទារក ស្នាក់នៅមណ្ឌលសុវត្ថិភាពចំនួន៣ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ដែលជាជំនួយឧបត្ថម្ភ របស់អង្គការសម្ព័ន្ធចាប់ដៃ អង្គការ ERIKS និង អង្គការ AIM
  - បានចូលរួមពិធីបើក "សិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាលល្បង នូវគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" នៅខេត្តត្បូងឃ្មុំ។